ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តត្បូងឃ្មុំ

# របាយការណ៍ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាម (SWOT) ដើម្បីកំណត់ពីសក្ដានុពល និងបញ្ហាប្រឈម ក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តត្បូងឃ្មុំ






រៀបរៀងដោយៈ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តត្បូងឃ្មុំ

ឆ្នាំ២០២៤

# បុព្វកថា

ក្នុងរយៈពេលត្រឹមតែ២ទសវត្សរ៍ចុងក្រោយនេះប៉ុណ្ណោះ ដែលប្រទេសកម្ពុជាទទួលបានសុខសន្តិភាពពេញលេញ នាំមកនូវការបង្រួបបង្រួមជាតិ និងផ្តល់ឱកាសឲ្យប្រទេសដែលធ្លាប់តែញាំញីដោយភ្លើងសង្គ្រាមរ៉ាំរ៉ៃមួយនេះអភិវឌ្ឍន៍ខ្លួនចេញពីស្ថានភាពដ៏ក្រីក្រ លំបាកយ៉ាប់យឺនជាទីបំផុតឈានមកដល់ដំណាក់កាលដ៏ល្អប្រសើរមួយដូចពេលបច្ចុប្បន្ននេះ។ កត្តានេះហើយដែលធ្វើអោយទំហំពាណិជ្ជកម្មរបស់កម្ពុជាមានប្រមាណ ៩,៥ ពាន់លានដុល្លារនៅឆ្នាំ ២០០៤ ហើយបានកើនឡើងជាបន្តបន្ទាប់រហូតដល់ ៩៧,៨៨ ពាន់លានដុល្លារនៅឆ្នាំ ២០២៣ ក្នុងនោះការនាំចេញសរុបរបស់កម្ពុជាមានប្រមាណ ២៣,៩៧ ពាន់លានដុល្លារអាម៉េរិក។ ផលិតផលក្នុងស្រុកសរុប (GDP) ក្នុងឆ្នាំ ២០០៤ មានប្រមាណ ៥,៣ ពាន់លានដុល្លារ ខណៈបច្ចុប្បន្នបានកើនឡើងដល់ ៤៣,១ ពាន់លានដុល្លារ មានការកើនឡើង ៨ ដង ស្របពេលនេះដែរអត្រាភាពក្រីក្ររបស់ពលរដ្ឋកម្ពុជា បានធ្លាក់ចុះជាលំដាប់ក្នុងអត្រាមធ្យមប្រចាំឆ្នាំ ១.៦ ភាគរយ ពី ៦០% ក្នុងឆ្នាំ២០០០ មកត្រឹម ១៦% ក្នុងឆ្នាំ២០២២ ហើយសេដ្ឋកិច្ចរបស់កម្ពុជាបានកើនឡើងជាង ៧ ភាគរយក្នុងមួយឆ្នាំ។ កំណើនដ៏ខ្ពស់នេះ បានធ្វើឱ្យកម្ពុជាចាកចេញពីឋានៈជាប្រទេសក្រីក្រ និងបានក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ ទាំងនេះបង្ហាញពីការកើនឡើងទំនុកចិត្តពីវិនិយោគិនឯកជន មកលើរាជរដ្ឋាភិបាលកម្ពុជា។ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភាបានបន្តផ្តល់អាទិភាពលើការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតភាពប្រកួតប្រជែង តាមរយៈការកែលម្អបរិយាកាសធុរកិច្ច ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញការវិនិយោគ ដែលជាបញ្ចកោណទី២ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ឆ្ពោះទៅពង្រឹងអភិបាលកិច្ច ដែលជាបរិយាកាសចាំបាច់សម្រាប់កិច្ចអភិវឌ្ឍប្រទេសជាតិ។

ដើម្បីគាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើតភាពប្រកួតប្រជែង តាមរយៈការកែលម្អបរិយាកាសធុរកិច្ច ការពង្រឹងប្រសិទ្ធភាព និងភាពទាក់ទាញការវិនិយោគ ខ្ញុំជឿជាក់ថា “**របាយការណ៍ ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាម (SWOT) ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តត្បូងឃ្មុំ**”នេះ នឹងក្លាយទៅជាផែនទីបង្ហាញផ្លូវមួយ សំរាប់អ្នកវិនិយោគ ពាណិជ្ជករ ដើម្បីជួយបង្កើនទំនុកចិត្ត និងការសំរេចចិត្តក្នុងការដាក់ទុនវិនិយោគក្នុងខេត្តត្បូងឃ្មុំ អោយកាន់តែមានភាពច្បាស់លាស់ និងមានភាពជឿជាក់ខ្ពស់។ ចំពោះសាធារណៈជន សិស្សនិស្សិតវិញរបាយការណ៍នេះ គឺជាឯកសាររឹងមួយដែលអាចយកធ្វើជាមូលដ្ឋានគ្រឹះក្នុងការសិក្សាស្រាវជ្រាវដើម្បីពង្រឹងសម្ថភាព ជំនាញ ចំណេះដឹងរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ពិសេសអាចអោយពួកគាត់បានយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពជាក់ស្តែងក្នុងមូលដ្ឋានក្នុងខេត្តត្បូងឃ្មុំ។ លទ្ធផលនៃរបាយការណ៍នេះក៏នឹងក្លាយទៅជាឧបករណ៍គន្លឹះមួយយ៉ាងសំខាន់ សំរាប់ថ្នាក់ដឹកនាំអង្គភាព ធ្វើជាឯកសារជំនួយស្មារតីក្នុងការសម្រេចចិត្ត ឲ្យបានត្រឹមត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាបន្តបន្ទាប់ទៀត។

ជាចុងក្រោយ ខ្ញុំសូមយកឱកាសនេះ វាយតម្លៃខ្ពស់ និងផ្តល់មូលវិចារដ៏ថ្លៃថ្លាចំពោះសហការី នៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តត្បូងឃ្មុំ និងអង្គភាពពាក់ព័ន្ធនានាទាំងអស់ ដែលបានខិតខំប្រឹងប្រែងអនុវត្តការងារយ៉ាងសកម្ម ក្នុងការរៀបចំចងក្រងនូវរបាយការណ៍នេះ រហូតសម្រេចបានលទ្ធផលល្អប្រសើរ គួរជាទីលើកទឹកចិត្ត។ ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំក៏សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានផ្តួចផ្តើមអោយមានការរៀបចំចងក្រងនូវរបាយការណ៍នេះ ព្រមទាំងផ្តល់នូវការគាំទ្រទាំងការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស និងសូមថ្លែងអំណរគុណដល់មន្ទីរ-អង្គភាពជុំវិញខេត្ត ដែលបានផ្តល់កិច្ចសហការល្អ ក្នុងការប្រមូល និងចងក្រងទិន្នន័យពាក់ព័ន្ធនានា។ ខ្ញុំសូមជូនពរសហការី នៃមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត មន្ទីរ អង្គភាពជុំវិញខេត្តទាំងអស់ សូមទទួលបានសុខភាពល្អបរិបូណ៌ សុភមង្គលក្នុងគ្រួសារ និងជោគជ័យ គ្រប់ភារកិច្ចការងារ។

ថ្ងៃចន្ទ ១កើត ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ត្បូងឃ្មុំ, ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២៤

**អភិបាលខេត្ត**

ប៉ែន_កុសល្យ

# អារម្ភកថា

ខេត្តត្បូងឃ្មុំ គឺជាអតីតរាជធានីបុរាណល្បីរឹងមាំមួយនៃព្រះបាទស្រីជេដ្ឋា(ស្តេចកន) នៅចន្លោះឆ្នាំ ១៥១២-១៥២៥ នៃគ្រឹះសករាជ ម្យ៉ាងទៀតគេអាចស្គាល់ខេត្តត្បូងឃ្មុំបានយ៉ាងច្បាស់តាមរយៈរឿងព្រេងនិទានអក្សរសិល្ប៍ខ្មែរ **ទុំទាវ** ដែលជាប្រវត្តស្នេហាស្មោះស្ម័គ្រ បានកើតឡើងនៅលើទឹកដីខេត្តត្បូងឃ្មុំនេះឯង។ ចំពោះទីតាំងភូមិសាស្ត្រវិញ ត្បូងឃ្មុំគឺជាខេត្តមួយស្ថិតនៅភាគខាងត្បូងនៃប្រទេសកម្ពុជា ដែលបំបែកចេញពីខេត្តកំពង់ចាម ដោយកាត់យកក្រុងចំនួនមួយ និងស្រុកចំនួន៦ គឺក្រុងសួង ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកក្រូចឆ្មារ ស្រុកតំបែរ ស្រុកពញាក្រែក និងស្រុកមេមត់ ដែលមានសង្កាត់ចំនួន០២ និងឃុំចំនួន៦២ ស្មើនឹង៨៧៥ភូមិ មានព្រំប្រទល់ជាប់ខេត្តក្រចេះ កំពង់ចាម ព្រៃវែង និងប្រទេសវៀតណាម។ ប្រជាពលរដ្ឋសរុបចំនួន ៨៦០,០៦៥នាក់ ផលិតផលក្នុងស្រុកសរុបសំរាប់មនុស្សម្នាក់(GDP per capita)ស្មើ ១,៥៩៧ដុល្លារ/នាក់ ក្នុងឆ្នាំ២០២២។ បច្ចុប្បន្នខេត្តត្បូងឃ្មុំ កំពុងតែបោះជំហានទៅមុខជាបន្តបន្ទាប់ ក្នុងការអភិវឌ្ឍន៍ លើគ្រប់វិស័យ សំដៅសំរេចអោយបានតាមគោលដៅរបស់រាជរដ្ឋាភិបាលដែលបានកំណត់ទុកសំរាប់ឆ្នាំ២០៣០ និងឆ្នាំ២០៥០ ដូចមានក្នុង *"យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា"* ។

ដោយមើលឃើញពីតម្រូវការ និងភាពចាំបាច់នូវព័ត៌មានមួយចំនួនដែលមានភាពគ្រប់ជ្រុងជ្រោយ អាចជឿជាក់បាននៃទិដ្ឋភាពសង្គម-សេដ្ឋកិច្ចក្នុងខេត្តត្បូងឃ្មុំ ដើម្បីទាក់ទាញការវិនិយោគ និងប្រើប្រាស់ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ខេត្ត អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានផ្តួចផ្តើមអោយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ធ្វើការរៀបចំនូវ ***"របាយការណ៍ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគ ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាម (SWOT) ដើម្បីកំណត់ពីសក្តានុពល និងបញ្ហាប្រឈមក្នុងកិច្ចអភិវឌ្ឍន៍របស់ខេត្តត្បូងឃ្មុំ"*** ក្នុងគោលបំណង ដើម្បីប្រើប្រាស់ជាគុណប្រយោជន៍ ក្នុងការតាមដានត្រួតពិនិត្យអំពីស្ថានភាព សេដ្ឋកិច្ច និងសង្គមក្នុងខេត្តជាប្រចាំ និងធ្វើការកំណត់នូវគុណវុឌ្ឍិដែលមានក្នុងខេត្ត ព្រមទាំងស្វែងរកភាពខ្សោយដើម្បីធ្វើការកែប្រែ។ របាយការណ៍នេះ ក៏បានបង្ហាញនូវស្ថានភាពរួមរបស់ខេត្ត និងស្ថានភាពតាមវិន័យសំខាន់ៗនានា ព្រមទាំងមានការបង្ហាញបន្ថែមនូវទិន្នន័យតាមវិស័យ ដើម្បីអោយអ្នកអាន ឬអ្នកប្រើប្រាស់មានភាពងាយយល់ និងច្បាស់លាស់។ ស្ថិតក្រោមកម្មវិធីកំណែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របាយការណ៍នេះបានរៀបចំឡើងចំនួន២លើករួចមកហើយ ពោលគឺក្នុងឆ្នាំ២០២២ និងឆ្នាំ២០២៣ ជាវឌ្ឍនៈភាព របាយការណ៍នេះត្រូវបានធ្វើបច្ចុប្បន្នភាពទិន្នន័យជាបន្តបន្ទាប់ ដើម្បីធានាថា រាល់អត្ថន័យ ខ្លឹមសារ និងទិន្នន័យក្នុងរបាយការណ៍នេះគឺជាទិន្នន័យថ្មី ដែលអាចជឿជាក់បានក្នុងការយកទៅប្រើប្រាស់បន្តទៀត។ ថ្វីបើស្ថានភាពសេដ្ឋកិច្ច សង្គម និង(SWOT)ត្រូវបានរៀបរាប់ក្នុងរបាយការណ៍នេះពិតមែន ប៉ុន្តែចំពោះការវិភាគ ពិនិត្យស៊ីជំរៅនៅតាមវិស័យនិមួយៗ គឺនៅមានកំរិតនៅឡើយ ដោយហេតុថាវិសាលភាពនៃការសិក្សាក្នុងរបាយការណ៍នេះមានភាពជាទូទៅ ទូលំទូលាយ សម្រាប់ស្ថានភាពជារួមរបស់ខេត្តតែប៉ុណ្ណោះ។ ក្នុងដំណើរការនៃការរៀបចំរបាយការណ៍ប្រចាំឆ្នាំ២០២៣ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបានប្រើប្រាស់អភិក្រមដោយកៀរគរការ ចូលរួមចំណែកពីគ្រប់តួអង្គពាក់ព័ន្ធ ដែលក្នុងនោះ រួមមាន៖ មន្ត្រី

រាជការក្នុងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខ្លួនឯងផ្ទាល់ មន្ទីរជំនាញ អង្គភាពពាក់ព័ន្ធតាមវិស័យ ព្រមទាំងរដ្ឋបាលខេត្ត និងក្រុងស្រុកនានា។ ការកៀរគរការចូលរួមនេះ រួមមាន ការផ្តល់នូវទិន្នន័យចាំបាច់ ការផ្តល់ធាតុចូល ការផ្តល់របាយការណ៍ និង ការឆ្លើយតបទៅនឹងសំណួរ ដែលរៀបចំដោយមន្ទីរផង ព្រមទាំងការចុះទៅ ប្រមូលព័ត៌មានដោយផ្ទាល់នៅការដ្ឋានដែលមានការពាក់ព័ន្ធផង។

ជាចុងក្រោយ, ក្នុងនាម មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត និង រូបខ្ញុំផ្ទាល់ សូមសម្តែងការដឹងគុណ និង ថ្លែងអំណរគុណដ៏ជ្រាលជ្រៅ បំផុតជូនចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធាន គ.ហ.ស. ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ និង ផ្តល់អនុសាសន៍ណែនាំដ៏មានតម្លៃ និង តម្រង់ទិសទាំងការរៀបចំ និង ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យសម្រេចជោគជ័យ និង ប្រកបដោយចីរភាព។ ទន្ទឹមនេះ, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម ប៉ែន កុសល្យ** អភិបាលនៃគណៈអភិបាលខេត្ត ដែលបានគាំទ្រ និងសម្របសម្រួលក្នុងការរៀបចំរបាយការណ៍នេះឡើង។ សូមថ្លែងអំណរគុណចំពោះក្រុមការងាររបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលផ្តល់ការគាំទ្រទាំងជំនួយហិរញ្ញវត្ថុ និងជំនួយសំភារៈ បច្ចេកទេស, សហការីនៃមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត, មន្ទីរជំនាញ អង្គភាពជុំវិញខេត្ត ដែលបានចូលរួមផ្តល់ទិន្នន័យ និងធាតុចូលសំខាន់ៗ រហូតមកដល់របាយការណ៍ត្រូវបានរៀបចំរួចរាល់នាពេលនេះ។

ថ្ងៃ សុក្រ ១២ រោច ខែ មិគសិរ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

ត្បូងឃ្មុំ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០២៤

**ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត**

**គីម ធិតា្យ**

# មាតិកានុក្រម


**បុព្វកថា** ....................... i

**អារម្ភកថា** ....................... ii

**មាតិកានុក្រម** ....................... v

**១-សេចក្តីផ្តើម** ....................... 1

**២-ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច** ....................... 2

២.១-ទិដ្ឋភាពទូទៅ ....................... 2

ទីតាំងភូមិសាស្ត្រ ....................... 2

ស្ថានភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រ ....................... 4

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ....................... 6

ពាណិជ្ជកម្ម ....................... 6

២.២-វិស័យកសិកម្ម ....................... 7

ប្រព័ន្ធស្រោចស្រព ....................... 12

ការដាំដុះ ....................... 12

២.៣-សកម្មភាពនៃវិស័យសេវាកម្ម និងកម្មន្តសាល ....................... 14

២.៤-វិស័យទេសចរណ៍ ....................... 15

២.៥-វិស័យហិរញ្ញវត្ថុ ....................... 16

ចំនួនប្រតិបត្តិករឥណទាន ....................... 16

ការប្រើប្រាស់ឥណទាន នៅតាមក្រុង/ស្រុក ....................... 17

២.៦-វិស័យសុខាភិបាល និងអប់រំ ....................... 20

សុខាភិបាល ....................... 20

ការអប់រំ ....................... 22

**៣- ការវិភាគភាពខ្លាំង** ( Strengths )**ភាពខ្សោយ** ( Weakness ) **ឱកាស** ( Opportunities ) **និងការគំរាមកំហែង** ( Threats ) ....................... 24

៣.១-ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង ....................... 25

ភាពខ្លាំង Strengths ....................... 25

ភាពខ្សោយ Weaknesses ....................... 28

ឱកាស Opportunities ....................... 29

ការគំរាមកំហែងThreats ....................... 30

៣.២-ការវិភាគខ្វែងគ្នារវាងភាពខ្លាំងភាពខ្សោយឱកាសនិងការគំរាមកំហែង ....................... 31

**៤-សេចក្តីសន្និដ្ឋាន** ....................... 33

**ឯកសារយោង** ....................................................................................................................35
**ឧបសម្ព័ន្ធ**........................................................................................................................36

## ១-សេចក្តីផ្តើម

ខេត្តត្បូងឃ្មុំត្រូវបានបង្កើតឡើងដោយ យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០៣/១៤៤៥ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ដោយកាត់យកក្រុងចំនួនមួយ និងស្រុកចំនួន៦ ពីខេត្តកំពង់ចាម គឺក្រុងសួង ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកក្រូចឆ្មារ ស្រុកតំបែរ ស្រុកពញាក្រែក និងស្រុកមេមត់ ដែលមានសង្កាត់ចំនួន០២ និងឃុំចំនួន៦២ ស្មើនឹង៨៧៥ភូមិ។ ខេត្តត្បូងឃ្មុំស្ថិតនៅទិសបូព៌ា នៃប្រទេសកម្ពុជា មានចម្ងាយប្រមាណ១៦៦គ.ម ពីរាជធានីភ្នំពេញ តាមផ្លូវជាតិលេខ៧។ ខេត្តត្បូងឃ្មុំមានព្រំប្រទល់ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងជើងជាប់នឹងខេត្តក្រចេះ ខាងលិចជាប់នឹងខេត្តកំពង់ចាម ខាងត្បូងជាប់នឹងខេត្តព្រៃវែង ដែលមានទីរួមខេត្តស្ថិតនៅភូមិនិគមន៍លើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ។ ខេត្តត្បូងឃ្មុំមានផ្ទៃដីសរុប៥,២៥០.៥១គ.ម$^{២}$ មានគ្រួសារសរុបចំនួន១៩៩,២៤៧គ្រួសារ ប្រជាពលរដ្ឋសរុបចំនួន ៨៦០,០៦៤នាក់ ក្នុងនោះស្ត្រីមានចំនួន ៤៣៥,០៨៤នាក់ ផលិតផលក្នុងស្រុកសរុបសំរាប់មនុស្សម្នាក់(GDP per capita)ស្មើ ១,៥៩៧ដុល្លារ/នាក់ ក្នុងឆ្នាំ២០២២ និងទំហំសេដ្ឋកិច្ចខេត្តត្បូងឃ្មុំមានចំនួន ១,៤១០.៧លានដុល្លារអាមេរិកក្នុងឆ្នាំ២០២២។

ការរៀបចំនូវរបាយការណ៍ ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច និងការវិភាគភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង របស់ខេត្តត្បូងឃ្មុំនេះ ធ្វើឡើងក្រោមការផ្តួចផ្តើមរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ របាយការណ៍នេះរៀបចំឡើងក្នុងទម្រង់ជាការប្រមូលផ្តុំនូវនិន្នន័យពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើការសិក្សានិងវិភាគលើកត្តាគន្លឹះសំខាន់ៗមួយចំនួន ដែលគាំទ្រដល់ការរៀបចំផែនការយុទ្ធសាស្ត្រនានារបស់អង្គភាព ដែលកត្តាសំខាន់ៗ ទាំងនោះត្រូវបានចែកចេញជាពីរកត្តាធំៗគឺៈ កត្តាខាងក្នុង (ភាពខ្លាំង និងភាពខ្សោយ) និងកត្តាខាងក្រៅ (ឱកាស និងការគំរាមកំហែង)។ លទ្ធផលនៃរបាយការណ៍នេះក៏នឹងក្លាយទៅជាឧបករណ៍គន្លឹះមួយយ៉ាងសំខាន់ សំរាប់ថ្នាក់ដឹកនាំពោលគឺរដ្ឋបាលគ្រប់លំដាប់ថ្នាក់អាចធ្វើជាឯកសារជំនួយស្មារតីក្នុងការសម្រេចចិត្ត ឲ្យបានត្រឹមត្រូវក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍។ ចំពោះអ្នកវិនិយោគ ពាណិជ្ជករ របាយការណ៍នេះពិតជានឹងក្លាយទៅជាផែនទីបង្ហាញផ្លូវមួយដែលជួយអោយការសំរេចចិត្តដាក់ទុនវិនិយោគក្នុងខេត្តត្បូងឃ្មុំ កាន់តែមានភាពច្បាស់លាស់ប្រកបដោយភាពជឿជាក់ខ្ពស់។ ចំពោះសាធារណៈជន សិស្សនិស្សិតរបាយការនេះ គឺជាឯកសាររឹងមួយដែលអាចយកធ្វើជាមូលដ្ឋានគ្រឹះក្នុងការសិក្សា ស្រាវជ្រាវដើម្បីពង្រឹងសមត្ថភាព ជំនាញ ចំណេះដឹងរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ពិសេសអាចអោយពួកគាត់បានយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពក្នុងមូលដ្ឋាន ដែលខ្លួនកំពុងរស់នៅ។

ការសិក្សារ និងការវិភាគក្នុងរបាយការណ៍នេះ មានគោលបំណងសំខាន់ៗដូចជាៈ ធ្វើការកំណត់ភាពខ្លាំង ឬគុណវុឌ្ឍិដែលខេត្តមានដើម្បីបន្តពង្រឹងបន្ថែមលើកត្តាទាំងនោះ ធ្វើការកំណត់ភាពខ្សោយដើម្បីកែប្រែនូវចំនុចខ្សោយទាំងនោះ ការចាប់យកឱកាសល្អៗដែលជាគុណប្រយោជន៍សំរាប់ខេត្ត ព្រមទាំងកំណត់បាននូវការ

គំរាមកំហែងដែលអាចកើតមានដើម្បីអោយយើងអាចបង្កើតការការពារដ៏ល្អ និងធ្វើការរៀបចំនូវមូលដ្ឋានគ្រឹះដ៏រឹងមាំ និងរៀបចំផែនការយុទ្ធសាស្ត្រអនុវត្តប្រកបដោយប្រសិទ្ធិភាព។

ក្នុងរបាយការណ៍ និងការវិភាគខាងក្រោមនេះ នឹងបង្ហាញយ៉ាងច្បាស់ នូវទិដ្ឋភាពទូទៅក្នុងខេត្តត្បូងឃ្មុំ រួមមាន៖ ស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ ស្ថានភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម កសិកម្ម សុខាភិបាល អប់រំ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងៗជាដើម។ ដើម្បីអោយយល់កាន់តែច្បាស់ ក្នុងរបាយការណ៍នេះនឹងធ្វើការបកស្រាយពន្យល់នៅតាមវិស័យនិមួយៗដូចជា វិស័យអប់រំ វិស័យសេវាកម្មនិងកម្មន្តសាល វិស័យទេសចរណ៍ វិស័យហិរញ្ញវត្ថុ វិស័យសុខាភិបាល និងវិស័យកសិកម្មជាដើម។ល។ ខ្លឹមសារសំខាន់នៃរបាយការណ៍ និងការវិភាគនេះគឺ៖

- ពិនិត្យមើលអំពីទិដ្ឋភាពសេដ្ឋកិច្ច សង្គមក្នុងខេត្តត្បូងឃ្មុំ តាមវិស័យនិមួយៗ
- ការកំណត់ និងវិភាគរកភាពខ្លាំង ភាពខ្សោយ ឱកាស និងបញ្ហាប្រឈម ដែលមានក្នុងខេត្តត្បូងឃ្មុំ
- កំណត់ភូមិសាស្ត្រ ដែលមានលក្ខណអំណោយផល ដែលជាជំនួយស្មារតីដល់វិនិយោគ
- ធ្វើសេចក្តីសន្និដ្ឋានរួម លើរបាយការណ៍ និងការវិភាគខាងលើ ដើម្បីកំណត់យុទ្ធសាស្ត្រសមស្របមួយ។

រាល់ទិន្នន័យ ការវិភាគ និងសេចក្តីអធិប្បាយក្នុងរបាយការណ៍នេះ អាចនឹងក្លាយទៅជាមគ្គុទេសក៍ ដ៏សំខាន់សំរាប់អ្នកវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុក ដើម្បីធ្វើសេចក្តីសម្រេចចិត្តក្នុងការដាក់ទុនវិនិយោគក្នុងខេត្តត្បូងឃ្មុំ ទៅតាមសក្តានុពលនៃតំបន់នីមួយៗ ដែលនឹងអាចស្រូបទាញនូវការងារយ៉ាងច្រើនជូនប្រជាពលរដ្ឋក្នុងស្រុក សំដៅធ្វើអោយជីវភាពប្រជាជន មានការកើនឡើង ក៏ដូចជាការជំរុញសេដ្ឋកិច្ចក្នុងស្រុកឱ្យមានការរីកចម្រើនផងដែរ។ ចំពោះសាធារណៈជន និងសិស្ស-និស្សិត រាល់ទិន្នន័យ នឹងអាចក្លាយជាមូលដ្ឋានក្នុងការសិក្សាស្វែងយល់បន្ត។

# ២-ទិដ្ឋភាពសង្គម-សេដ្ឋកិច្ច

## ២.១-ទិដ្ឋភាពទូទៅ

### ទីតាំងភូមិសាស្ត្រ

ខេត្តត្បូងឃ្មុំស្ថិតនៅទិសបូព៌ា នៃប្រទេសកម្ពុជាមានចម្ងាយប្រមាណ១៦៦គ.ម ពីរាជធានីភ្នំពេញតាមផ្លូវជាតិលេខ៧ ខេត្តត្បូងឃ្មុំមានព្រំប្រទល់ ខាងកើតជាប់នឹងប្រទេសវៀតណាម ខាងជើងជាប់នឹងខេត្តក្រចេះ ខាងលិចជាប់នឹងខេត្តកំពង់ចាម ខាងត្បូងជាប់នឹងខេត្តព្រៃវែង។ ដែលមានទីរួមខេត្តស្ថិតនៅភូមិនិគមន៍លើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ។ បច្ចុប្បន្នខេត្តត្បូងឃ្មុំមានក្រុងចំនួនមួយ និងស្រុកចំនួន០៦ គឺក្រុងសួង ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកក្រូចឆ្មារ ស្រុកតំបែរ ស្រុកពញាក្រែក និងស្រុកមេមត់ ដែលមានសង្កាត់ចំនួន០២ និងឃុំចំនួន៦២ ស្មើនឹង៨៧៣ភូមិ មានផ្ទៃដីសរុប៥,២៥០.៥១គ.ម$^{២}$។

ខេត្តត្បូងឃ្មុំចែកជា តំបន់៣ សំខាន់ៗមានដូចជា៖

១.តំបន់វាលទំនាប ស្ថិតនៅចន្លោះស្រុកត្បូងឃ្មុំ ស្រុកពញាក្រែក និងស្រុកអូររាំងឪ ។

២.តំបន់ដីសណ្តទន្លេមេគង្គ ស្ថិតនៅប្របតាមដងទន្លេ នៃស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ។

៣.តំបន់ខ្ពង់រាបដីក្រហម ឬដីសិលាបាសាល់ ស្ថិតនៅស្រុកត្បូងឃ្មុំ អូររាំងឪ ពញាក្រែកនិងស្រុកមេមត់។

*រូបភាពទី ១ ផែនទីភូមិសាស្ត្រខេត្តត្បូងឃ្មុំ*



## ស្ថានភាពសេដ្ឋកិច្ច និងប្រជាសាស្ត្រ

ផលិតផលក្នុងស្រុកសរុប(GDP) សំរាប់ខេត្តត្បូងឃ្មុំមានចំនួន ១,៨១០.៧លានដុល្លារ ក្នុងឆ្នាំ២០២២ ជាមួយអត្រាកំណើនGDPប្រចាំឆ្នាំ៣.៣%។ ផលិតផលក្នុងស្រុកសរុបសំរាប់មនុស្សម្នាក់(GDP per capita)ស្មើ ១,៥៩៧ដុល្លារក្នុងឆ្នាំ២០២២។

*រូបភាពទី ២ អត្រាកំណើនសេដ្ឋកិច្ចខេត្តត្បូងឃ្មុំគិតចាប់ពីឆ្នាំ២០១៩ ដល់២០២២*




| | 2019 | 2020 | 2021 | 2022 |
|---|---|---|---|---|
| កំណើនGDP | 6.4% | -0.8% | 2.8% | 3.3% |
| បម្រែបម្រួលអត្រាប្តូរប្រាក់ | 0.49% | 0.49% | -0.37% | 0.98% |
| អតិផរណា | 1.8% | 2.8% | 3.1% | 5.2% |

*ប្រភពឯកសារ:មន្ទីរផែនការខេត្តត្បូងឃ្មុំឆ្នាំ២០២២*

ជាមួយនឹងការងើបឡើងវិញយ៉ាងឆាប់រហ័យបន្ទាប់ពីទទួលរងឥទ្ធិពលជំងឺរាតត្បាតកូវីង ១៩ សេដ្ឋកិច្ចខេត្តត្បូងឃ្មុំមាននិន្នាការ ងើបឡើងវិញយ៉ាងឆាប់រហ័សដោយក្នុងឆ្នាំ២០២២ អាចសំរេចបានកំណើនGDP ៣.៣%ប្រចាំឆ្នាំ ខណ:ដែលGDP សំរាប់ប្រទេសកម្ពុជាក្នុងឆ្នាំដដែលសំរេចបាន៥.១%។ ការអូសបន្លាយសង្គ្រាមរវាង ប្រទេសរ៉ុស្សីជាមួយប្រទេសអ៊ុយក្រែននៅតែបន្ត បូករួមជាមួយស្ថានភាពថ្មីនៃសង្គ្រាមនៅមជ្ឈិមបូព៌ា បានធ្វើអោយអត្រាអតិផរណាសាកលនៅតែមានកំរិតខ្ពស់ ពិសេសលើវិស័យប្រេងឥន្ទន: ដែលជាកត្តានាំអោយកំណើនសេដ្ឋកិច្ចមាននិន្នាការកើនឡើងទាប។ ដោយហេតុថាប្រជាជនក្នុងខេត្តត្បូងឃ្មុំ ភាគច្រើនប្រកបរបរកសិកម្ម ដែលជាវិស័យមួយរងឥទ្ធិពលតិចតួចពីវិបត្តិខាងលើ ផ្ទុយទៅវិញនិន្នាការតម្រូវការស្បៀងលើពិភពលោកមានការកើនឡើងធ្វើអោយតម្លៃកសិផលក្នុងឆ្នាំ២០២៣ មានលក្ខណ:ល្អប្រសើ ដែលធ្វើអោយស្ថានភាពសេដ្ឋកិច្ចគ្រួសារនិមួយៗរបស់កសិករអាចទ្រទ្រង់បាននូវវិបត្តិសាកលនេះ។

ប្រជាពលរដ្ឋ សរុប១៩៩,២៤៧គ្រួសារ មានប្រជាពលរដ្ឋសរុប ៨៦០,០៦៤នាក់ ស្រ្តីសរុបចំនួន ៨៣៥,០៨៤នាក់ បុរសសរុប ចំនួន៤២៤,៩៨០នាក់ អ្នកមានអាយុក្រោម១៧ឆ្នាំមាន ៣៩.៦៣% នៃប្រជាជនសរុប និងអ្នកមានអាយុពី ១៨ ដល់៦០ឆ្នាំ មាន៥៥.៦៩% នៃប្រជាជនសរុប ជាមួយអត្រាកំណើនប្រចាំឆ្នាំ-0.៩៦%។ ទិន្នន័យនេះបង្ហាញថា ខេត្តត្បូងឃ្មុំសំបូរកំលាំងពលកម្ម ដោយហេតុថាមនុស្សគ្រប់អាយុធ្វើការមានរហូតទៅដល់ជាង៥៥% នៃប្រជាជនសរុបដែលអាចផ្គត់ផ្គង់បានតាមតម្រូវការទីផ្សារនៃកំលាំងពលកម្មក្នុងខេត្ត។

ខាងក្រោម ជាតារាងទិន្នន័យបង្ហាញ ពីចំនួនប្រជាជនតាមបណ្ដាក្រុង/ស្រុកៈ

*រូបភាពទី ៣ ចំនួនប្រជាជននិងដង់ស៊ីតេប្រជាជនតាមបណ្តាក្រុង/ស្រុកឆ្នាំ២០២៣*




*ប្រភពឯកសារៈមន្ទីរផែនការខេត្តត្បូងឃ្មុំឆ្នាំ២០២៣*

ស្រុកដែលមានប្រជាជនច្រើនជាងគេមាន ស្រុកត្បូងឃ្មុំ ស្រុកមេមត់ និងស្រុកពញាក្រែក ដោយឡែក ស្រុកដែលមានប្រជាជនតិចជាងគេមាន ក្រុងសួង ស្រុកតំបែរ និងស្រុកអូររាំងឪ។ តំបន់ដែលមានប្រជាជនរស់នៅច្រើនកុះករមានៈ ក្រុងសួង ស្រុកអូររាំងឪ និងស្រុកត្បូងឃ្មុំ។

*រូបភាពទី ៤ %ប្រជាជនអាយុ១៨-៦០ឆ្នាំក្នុងឆ្នាំ២០២៣*




*ប្រភពឯកសារៈមន្ទីរផែនការខេត្តត្បូងឃ្មុំ*

យោងតាមក្រាហ្វិកខាងលើ ខេត្តត្បូងឃ្មុំមានប្រជាជនអាយុ ពី១៨ ដល់៦០ឆ្នាំ ប្រមាណ៥៦% នៃប្រជាជនសរុបក្នុងនោះ ប្រមាណ៤៩%ជាស្ត្រី។ ស្រុកដែលមានអត្រាប្រជាជនអាយុ១៨-៦០ឆ្នាំ ច្រើនជាងគេគឺ ស្រុកពញាក្រែក និងស្រុកមេមត់។ លក្ខណប្រជាសាស្ត្របែបនេះ ធ្វើអោយខេត្តត្បូងឃ្មុំជាខេត្តមួយដែលមាន សក្តានុពលខ្លាំង ក្នុងការផ្គត់ផ្គង់កំលាំងពលកម្មទាំងក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម។

## ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ខេត្តត្បូងឃ្មុំមានផ្លូវជាតិធំៗចំនួន០៦ខ្សែគឺផ្លូវជាតិលេខ៧ លេខ៨ លេខ១១ លេខ៧២ លេខ៧៣ លេខ៧១C ដែលតភ្ជាប់ពីទីរួមខេត្តទៅក្រុង-ស្រុកឃុំសង្កាត់ និងភូមិ ស្ពានឆ្លងកាត់ទន្លេមេគង្គចំនួន០២ គឺស្ពានមិត្តភាព កម្ពុជា-ជប៉ុនគីហ្សូណា និងស្ពានមិត្តភាពកម្ពុជា-ចិន ស្ទឹងត្រង់-ក្រូចឆ្មារ និងកំពង់ផែរ មួយកន្លែង។ ខេត្តត្បូងឃ្មុំជាខេត្តមួយមានលក្ខណៈអំណោយផលខាងផ្នែកដឹកជញ្ជូនទាំងផ្លូវគោក និងផ្លូវទឹក។ ចំពោះផ្លូវគោកសរុបក្នុងខេត្តមានប្រភេទផ្លូវក្រាលកៅស៊ូប្រវែង១,១១៣km ផ្លូវបេតុងប្រវែង៣៥៨km និងផ្លូវក្រាលគ្រួសក្រហមប្រវែង១,១០៩km ផ្លូវទឹកមានបណ្តោយតាមដងទន្លេមេគង្គមានប្រវែងសរុប៧៤km ។

*រូបភាពទី ៥ ប្រវែងផ្លូវតាមបណ្តាក្រុង/ស្រុកឆ្នាំ២០២៣*

| ល.រ | ប្រភេទផ្លូវ | តំបែរ | ក្រូចឆ្មារ | មេមត់ | អូររាំងឪ | ពញាក្រែក | សួង | ត្បូងឃ្មុំ | **សរុប** |
|---|---|---|---|---|---|---|---|---|---|
| 1 | ផ្លូវក្រាលកៅស៊ូ(km) | 163 | 107 | 262 | 85 | 229 | 65 | 201 | 1,113 |
| 2 | ផ្លូវចាក់បេតុង(km) | 93 | 69 | 46 | 48 | 21 | 11 | 70 | 358 |
| 3 | ផ្លូវក្រាសគ្រួសក្រហម(km) | 159 | 121 | 190 | 80 | 211 | 47 | 302 | 1,109 |
| | សរុប | 415 | 298 | 498 | 212 | 461 | 123 | 573 | 2,580 |

*ប្រភពឯកសារៈឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ចសេដ្ឋកិច្ចសង្គម(ទិន្នន័យមូលដ្ឋានឃុំសង្កាត់ខែធ្នូឆ្នាំ២០២៣)*

យោងតាមរយៈរូបភាពទី ៥ ខាងលើ យើងពិនិត្យឃើញថាស្រុក ដែលមានប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនច្រើនជាងគេមានដូចជា ស្រុកត្បូងឃ្មុំ ស្រុកមេមត់ ស្រុកពញាក្រែក និងស្រុកតំបែរ ដោយឡែក ស្រុកដែលមានប្រព័ន្ធគមនាគមន៍ ដឹកជញ្ជូនតិចជាងគេមាន ស្រុកអូររាំងឪ និងក្រុងសួង។ តាមបណ្តា ក្រុង/ស្រុក ដែលមានប្រជាជនរស់នៅច្រើនកុះករ ត្រូវមានប្រព័ន្ធគមនាគមន៍ច្រើនដូចជា ក្រុងសួង និងស្រុកត្បូងឃ្មុំគឺជាការសមស្រប ប៉ុន្តែសំរាប់ស្រុកអូររាំងឪ ជាតំបន់ដែលមានប្រជាជនកុះករបន្ទាប់ពីក្រុងសួង ប៉ុន្តែប្រព័ន្ធគមនាគមន៍ ដឹកជញ្ជូននៅមានកម្រិតមធ្យមនៅឡើយ។

វិស័យគមនាគមន៍ គឺជាសរសៃឈាមសេដ្ឋកិច្ចជាតិ ដ៏សំខាន់មិនអាចខ្វះបាន សម្រាប់បម្រើដល់មធ្យោបាយសេវាដឹកជញ្ជូន និងការធ្វើដំណើររបស់ប្រជាពលរដ្ឋដែលមិនអាចខ្វះបាន។ **ផ្លូវ** គឺជាអាទិភាពគន្លឹះក្នុងចំណោមអាទិភាពគន្លឹះទាំងប្រាំ នៃយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់ការតភ្ជាប់ និងបង្កើនប្រសិទ្ធភាពនៃវិស័យដឹកជញ្ជូន និងឡូជីស្ទីក ក្នុងគោលបំណងបង្កើនផលិតភាព លើកកម្ពស់ការប្រកួតប្រជែងក្នុងតំបន់។

### ពាណិជ្ជកម្ម

ខេត្តត្បូងឃ្មុំជាខេត្តដែលមានសក្តានុពលសេដ្ឋកិច្ចសំខាន់ក្នុងការជំរុញវិនិយោគ និងសកម្មភាពចរាចរទំនិញ ទាំងផ្លូវគោកនិងផ្លូវទឹក ជាពិសេសខេត្តមានព្រំប្រទល់ជាប់ប្រទេសវៀតណាម ដែលធ្វើឱ្យសកម្មភាពពាណិជ្ជកម្មជាប់ព្រំដែនមានសន្ទុះកើន ឡើងជារៀងរាល់ឆ្នាំ។ ការចូលរួមជំរុញលើការផ្តល់សេវាពាណិជ្ជកម្មជូនវិ

ស្វ័យឯកជនឱ្យបានល្អឆាប់រហ័ស ប្រកបដោយតម្លាភាព និងជួយសម្របសម្រួលបែបបទនានាទាក់ទងជាមួយផ្នែកពាណិជ្ជកម្ម ការជួយរកទីផ្សារលក់ផលិតផលជូនប្រជាពលរដ្ឋ និងខិតខំប្រឹងប្រែងក្តាប់ពីព័ត៌មានទីផ្សារ ផ្សព្វផ្សាយព័ត៌មានទីផ្សារ ព័ត៌មានថ្លៃ ការជួយសម្របសម្រួលការចាប់ដៃគូពាណិជ្ជកម្ម។ បច្ចុប្បន្នខេត្តមានក្រុមហ៊ុន សាខាក្រុមហ៊ុន និងសហគ្រាស សរុបចំនួន៦៦៣ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ផ្សារសរុបចំនួន ៤២ ផ្សារ (ផ្សាររដ្ឋ១០ ផ្សារឯកជនចំនួន០៧ ផ្សារសហគមន៍១៦ ផ្សារបោះដុំ១ និងផ្សារក្រមួន៨)។

ខេត្តត្បូងឃ្មុំមានច្រកព្រំដែន ចំនួន០៧ ក្នុងនោះច្រកព្រំដែនអន្តរជាតិចំនួន០១ (ត្រពាំងផ្លុង) ច្រកព្រំដែនទ្វេភាគីចំនួន០២ (ដារ និងទន្លេចាម) និងច្រកទ្វារតំបន់ព្រំដែនចំនួន០៤ (ជាំក្រវៀន ដូនរ័ត្ន ចាន់មូល និងទន្លូង)។ ក្នុងឆ្នាំ២០២២ទំហំពាណិជ្ជកម្ម ទំនិញនាំចេញសរុប ទឹកប្រាក់ប្រមាណ ៤២១លានដុល្លារអាមេរិក និងទំនិញនាំចូលទឹកប្រាក់ប្រមាណ ៧០លានដុល្លារអាមេរិច។

រូបភាពទី ៦ ផលទំហំពាណិជ្ជកម្មខេត្តត្បូងឃ្មុំក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (គិតជាលានUSD)




*ប្រភពឯកសារៈទិន្នន័យនាំចេញនាំចូលទំនិញរបស់មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ*

ខេត្តត្បូងឃ្មុំមាន អតិរេកជញ្ជីងពាណិជ្ជកម្មក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះជាមួយប្រទេសវៀតណាម ថ្វីត្បិតតែការនាំចេញក្នុងរយៈពេល៣ឆ្នាំចុងក្រោយមានការធ្លាក់ចុះពិតមែន ប៉ុន្តែខេត្តត្បូងឃ្មុំនៅតែអាចរក្សាបាននូវ ភាពល្អប្រសើក្នុងការធ្វើពាណិជ្ជកម្ម ដែលការនាំចេញទាំងនោះភាគច្រើនជាកសិផលមានដូចជា៖ កៅស៊ូ ម្រេច ដំឡូងមី គ្រាប់ស្វាយចន្ទី ឈើ ពោត សណ្តែក និងអង្ករ។ យោងតាមអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ស្ថិតិការនាំចេញពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម ជារួមមានចំនួន២,៩៧២,៥៥៨ពាន់លានUSD កើនឡើងចំនួន១៣.១%ធៀបនឹងឆ្នាំ២០២២ ដោយឡែងសំរាប់ខេត្តត្បូងឃ្មុំការធ្លាក់ចុះនៃការនាំចេះក្នុងឆ្នាំ២០២៣ អាចបណ្តាលមកពី ការបើកដំណើការច្រកទ្វាពុំដែនបន្ថែមទៀតនៅតាមបណ្តាខេត្តជាប់ប្រទេសវៀតណាម ដែលធ្វើអោយទិន្នន័យនៃការនាំចេញនេះធ្លាក់ចុះ។

## ២.២-វិស័យកសិកម្ម

ខេត្តត្បូងឃ្មុំ ស្ថិតក្នុងតំបន់ខ្ពង់រាប នៃប្រទេសកម្ពុជា មានសណ្ឋានដីចែកចេញជាបីប្រភេទគឺ៖

- តំបន់ទំនាបដងទន្លេមេគង្គៈ តំបន់នេះស្ថិតនៅស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ជាតំបន់លិចទឹកនៅរដូវទឹកទន្លេមេគង្គឡើង ដែលជាហេតុធ្វើឱ្យដីនៅតំបន់នេះ មានជីវជាតិល្អសំរាប់ ការដាំដុះបន្លែ និងដំណាំផ្សេងៗ ដូចជាស្រូវ សណ្តែក ពោត ដំឡូងជ្វា ល្ង ថ្នាំជក់ជាដើម។ ប្រជាជនភាគច្រើមប្រកបរបរកសិកម្ម និងធ្វើការដាំដុះដំណាំរួមផ្សំនានា នៅរដូវប្រាំង និងដើមរដូវវស្សា ពិសេសនៅរដូវទឹកទន្លេមេគង្គស្រក។
- តំបន់វាលរាបៈ ស្ថិតនៅព្រំប្រទល់ ស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ និងស្រុកពញាក្រែក តំបន់នេះមានផ្ទៃដីរាបស្មើ ជាផ្ទៃទទួលរងទឹកភ្លៀង នៅរដូវវស្សាមានលក្ខណៈ អំណោយផលលើដំណាំស្រូវ វស្សា និងផ្នែកខ្លះនៃតំបន់នេះ ក៏អាចធ្វើស្រូវប្រាំងបានផងដែរ។ ប្រជាជនរស់នៅតំបន់នេះភាគបច្រើន ធ្វើស្រែនៅរដូវវស្សា បន្ទាប់ពីប្រមូលផលរួច ប្រជាជនខ្លះអាចធ្វើចំណាកស្រុកដើម្បីរកការងារធ្វើបន្ថែមទៀតនៅតាមបណ្តា រាជធានីខេត្តនានា។
- តំបន់ខ្ពង់រាបដីក្រហម ឬដីសិលាបាសាល់ៈ ស្ថិតនៅស្រុកត្បូងឃ្មុំ ស្រុកអូររាំងឪ ស្រុកពញាក្រែក និងស្រុកមេមត់។ ដីប្រភេទនេះមានជីវជាតិល្អណាស់ សម្រាប់ដំណាំគ្រប់ប្រភេទ ជាពិសេសដំណាំកសិឧស្សាហកម្មដូចជា កៅស៊ូ ស្វាយ ស្វាយចន្ទី ម្រេច ធុរេន ចេកអំបូង ដំឡូងមី មៀន សារម៉ាវ និងដំណាំហូបផ្លែជាច្រើនទៀត។ ប្រជាជនភាគច្រើនដាំដុះដំណាំរយៈពេលវែង ផ្ទៃដីដាំដុះច្រើន ដែលជាហេតុធ្វើអោយដង់ស៊ីតេប្រជាជននៅដំបន់នេះទាប ។

ដើម្បីចូលរួមចំណែកសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរបានផ្តល់សេវាផ្សព្វផ្សាយ បណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងសហការជាមួយស្ថាប័ន ជំនាញពាក់ព័ន្ធ អាជ្ញាធរ គ្រប់លំដាប់ថ្នាក់ ផ្នែកឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញឱ្យវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្នុងខេត្ត មានការអភិវឌ្ឍប្រកបដោយគុណភាព ប្រសិទ្ធភាព និងនិរន្តរភាព តាម រយៈការលើកកម្ពស់ផលិតភាពពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម និងការលើកកម្ពស់ការ ចិញ្ចឹមសត្វ និងវារីវប្បកម្ម ដោយយកចិត្តទុកដាក់ខ្ពស់លើការ ការពារ និងគ្រប់គ្រងធនធានព្រៃឈើ និង ជលផលប្រកបដោយចីរភាព។ ជាក់ស្តែងបរិមាណផលជលផលក្នុងឆ្នាំ២០២៣ មានប្រមាណ ១៤ ៦៥៥តោន ដែលមានតម្លៃប្រមាណ ២៩លានដុល្លាអាមេរិក ក្នុងនោះបានពីការនេសាទក្នុងដែននេសាទមានប្រមាណ ៥ ៦៥៩តោន បានពីការ នេសាទតាមវាលស្រែ មានប្រមាណ ៣ ១៨៩តោន បានពីវារីវប្បកម្មប្រមាណ ៥ ៨០៦តោន និងស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើស ជលផលបានចំនួន ៦៨ករណី (បញ្ជូនទៅតុលាការ ៤ករណី ពិន័យអន្តរការណ៍ ២ករណី និងបំផ្លាញចោលវត្ថុតាង នៅនឹងកន្លែង ៦២ករណី)

វិស័យកសិកម្មក៏មានបញ្ហាប្រឈមមួយចំនួនដូចជាៈ ការចំណាយទៅលើផលិតកម្មកសិកម្មខ្ពស់, ផលិតកម្មកសិកម្ម មិនមានលក្ខណៈប្រមូលផ្តុំ, ឥណទានមានអត្រាការប្រាក់ខ្ពស់, ខ្វះភាពប្រទាក់ក្រឡាគ្នារវាងផលិតកម្ម និងទីផ្សារ, ខ្វះមូលដ្ឋានកែច្នៃផលិតផលកសិកម្មក្នុងស្រុក, រចនាសម្ព័ន្ធគ្រប់គ្រង រចនាសម្ព័ន្ធផលិតកម្ម អាជីវកម្ម សេវាកម្ម របស់សហគមន៍កសិកម្ម មិនទាន់រឹងមាំ, គ្រោះធម្មជាតិជាដើម។

ប្រភេទដំណាំសំខាន់ៗ ក្នុងខេត្ត និងតាមបណ្តាស្រុកមានដូចជាៈ

រូបភាពទី ៧ តារាង ផ្ទៃដីដាំដុះ ឆ្នាំ២០២៣

| ល.រ | រាយមុខដំណាំ | ផ្ទៃដីប្រមូលផល (ហត) | |
|---|---|---|---|
| | | 2022 | 2023 |
| ១ | ដំណាំស្រូវ | 87,855.00 | 88,480.00 |
| ២ | ពោតស | 895.00 | 845.00 |
| ៣ | ដំឡូងផ្វា | 175.00 | 125.00 |
| ៤ | បន្លែគ្រប់មុខ | 1,745.00 | 1,960.00 |
| ៥ | ពោតក្រហម | 11,225.00 | 11,450.00 |
| ៦ | ដំឡូងមី | 53,135.00 | 52,875.00 |
| ៧ | សណ្តែកបាយ | 605.00 | 825.00 |
| ៨ | សណ្តែកដី | 270.00 | 170.00 |
| ៩ | ល្ង | 370.00 | 205.00 |
| ១០ | អំពៅ | 350.00 | 345.00 |
| ១១ | ថ្នាំជក់ | 1,550.00 | 1,235.00 |
| ១២ | ឪឡឹក | 25.00 | 55.00 |
| ១៣ | ឈូក | 450.00 | 430.00 |
| ១៤ | ចេក | 545.00 | 585.00 |
| ១៥ | ចេក (ចេកអំបូងលឿង) | 300.00 | 300.00 |
| ១៦ | ស្វាយចន្ទី | 8,290.00 | 7,675.00 |
| ១៧ | ដូង | 610.00 | 390.00 |
| ១៨ | ដូងក្រអូប | - | 15.00 |
| ១៩ | មៀន | 50.00 | 50.00 |
| ២០ | តាង៉ែន | 55.00 | 55.00 |

| ល.រ | រាយមុខដំណាំ | ផ្ទៃដីប្រមូលផល (ហត) | |
|---|---|---|---|
| | | 2022 | 2023 |
| ២១ | ស្វាយ(ស្វាយកែវល្មៀត) | 2,045.00 | 1,655.00 |
| ២២ | ល្មើ | 1.00 | 2.00 |
| ២៣ | មង្ឃុត | 133.00 | 55.00 |
| ២៤ | ទុរេន | 330.00 | 371.00 |
| ២៥ | ខ្នុរ | 155.00 | 155.00 |
| ២៦ | ទៀប | 150.00 | 145.00 |
| ២៧ | ក្រូចថ្លុង | 30.00 | 25.00 |
| ២៨ | ក្រូចក្វិច | 28.00 | 28.00 |
| ២៩ | ក្រូចឆ្មារ | 32.00 | 22.00 |
| ៣០ | ល្ហុង | 40.00 | 10.00 |
| ៣១ | កាហ្វេ | 5.00 | 5.00 |
| ៣២ | សារម៉ាវ | 200.00 | 200.00 |
| ៣៣ | ត្របែក | 40.00 | 30.00 |
| ៣៤ | ពុទ្រា | 25.00 | 25.00 |
| ៣៥ | ម្នាស់ | 55.00 | 55.00 |
| ៣៦ | ម្រេច | 2,134.00 | 3,270.00 |
| ៣៧ | ស្រកានាគ | 25.00 | 25.00 |
| ៣៨ | ចំប៉ាដក់ | 150.00 | 5.00 |
| ៣៩ | ឬស្សីផ្អែម | 24.00 | 24.00 |
| ៤០ | កៅស៊ូ | 64,863.61 | 79,456.68 |
| | សរុប | **238,965.61** | **253,633.68** |

*រូបភាពទី ៨ ផ្ទៃដីដាំដុះតាមបណ្តាក្រុងស្រុក*




*ប្រភពឯកសារៈមន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទខេត្តត្បូងឃ្មុំ*

ខេត្តត្បូងឃ្មុំមានផ្ទៃដីដាំដុះសរុប ៣៤៩,៣០៧ហិចតា ក្នុងនោះស្រុកដែលមានផ្ទៃដីដាំដុះធំៗ មានដូចជា ស្រុកមេមត់ មានផ្ទៃដីដាំដុះ សរុប ១០៨,៦៩៧ហិចតា ស្រុកតំបែរ មានផ្ទៃដីដាំដុះសរុប ៩៥,០៦៧ហិចតា និងស្រុកត្បូងឃ្មុំមានផ្ទៃដីដាំដុះសរុប ៦០,៩០៤ហិចតា។

*រូបភាពទី ៩ ដំណាំរយៈពេលវែងនិងរយៈពេលខ្លី*




តាមរយៈរូបភាពទី ៩ ខាងលើចំពោះដំណាំរយៈពេលខ្លីដូចជា÷ ស្រូវ ដំឡូងមី ពោត លូ សណ្តែង ជាដើម កសិករដាំដុះច្រើនជាងគេនៅ ស្រុកតំបែរ និងស្រុកត្បូងឃ្មុំ ដោយឡែក ចំពោះដំណាំរយៈពេលវែងមានដូចជា÷ កៅស៊ូ ស្វាយចន្ទី ម្រេច ស្វាយកែវរមៀតជាដើម កសិករដាំដុះច្រើននៅ ស្រុកមេមត់ តំបែរ និងត្បូងឃ្មុំ[1]។ យោងលើសណ្ឋានដីក្នុងស្រុកមេមត់ និងស្រុកត្បូងឃ្មុំ ភាគច្រើនជាប្រភេទដីក្រហម ដែលដីប្រភេទនេះមានលក្ខណៈអំណោយផលលើដំណាំរយៈពេលវែង បច្ចុប្បន្នតំបន់នេះប្រជាជនភាគច្រើនដាំដំណាំកៅស៊ូ ស្វាយចន្ទី ម្រេច និងធុរេនជាដើម ចំពោះដំណាំរយៈពេលខ្លី ថ្វីត្បិតតែស្រុកតំបែរមិនមែនជា

---

[1] ឧបសម្ព័ន្ធទី១. *តារាងដំណាំរយៈពេលវែង និងរយៈពេលខ្លី*

តំបន់មាត់ទន្លេ តែស្រុកនេះត្រូវបានក្រសួងកសិកម្ម កំណត់ធ្វើជាស្រុកអាទិភាពក្នុងការដាំដុះបន្លែដោយមានការគាំទ្របច្ចេកទេស និងសំភារៈហេតុនេះទិន្នន័យបានបង្ហាញថា ស្រុកតំបែរមានផ្ទៃដីដាំដុះដំណាំរយៈពេលខ្លីច្រើនជាងគេ។

រូបភាពទី ១០ %ប្រជាជនមានមុខរបរចម្បងជាកសិករឆ្នាំ២០២៣




*ប្រភពឯកសារៈឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ចសេដ្ឋកិច្ចសង្គម(ទិន្នន័យមូលដ្ឋានឃុំសង្កាត់ខែធ្នូឆ្នាំ២០២៣)*

ប្រជាជនក្នុងខេត្តត្បូងឃ្មុំ មានមុខរបរចម្បងជាកសិករ គិតជាមធ្យមមានចំនួន៧១% នៃប្រជាជនក្នុងខេត្តសរុប ក្នុងនោះ ស្រុកតំបែរមានប្រជាជាជន ជាកសិករចំនួនច្រើនជាងគេស្មើ៨៥% បន្ទាប់មកគឺស្រុកក្រូចឆ្មារមាន៨០% និងស្រុកពញាក្រែកមាន៧៨% ដោយឡែក ក្រុងសួងមានប្រជាជនមានមុខរបរជាកសិករស្មើ២៨% និងស្រុកត្បូងឃ្មុំមានស្មើ៧១%។ យោងតាមទិន្នន័យស្ថិតិឆ្នាំ២០២៣ ភាគរយប្រជាជនដែលប្រកបរបរចម្បងជាកសិករស្មើ៧១% ថយចុះ១០%ធៀបនឹងឆ្នាំ២០២២ និន្នាការនេះអាចបណ្តាលមកពីផ្លាស់ប្តូមុនរបររបស់ប្រជាជន ពីកសិកម្មទៅមុខរបរផ្សេងវិញ ដែលមានកម្រៃខ្ពស់ជាង ឬអាចបណ្តាលមកពីការកើនឡើងនៃតម្រូវការងារមិនមែនកសិកម្ម ក្នុងខេត្តត្បូងឃ្មុំ ដូចជាសិប្បកម្ម និងសេវាកម្ម។

រូបភាពទី ១១ តារាងសរុបគ្រឿងចក្រកសិកម្មឆ្នាំ២០២៣

| ល.រ | គ្រឿងចក្រ | ២០២២ | ២០២៣ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | តំបែរ | ក្រូចឆ្មារ | មេមត់ | អូររាំងឪ | ពញាក្រែក | សួង | ត្បូងឃ្មុំ | សរុប |
| 1 | ត្រាក់ទ័រ | **1,864** | 233 | 494 | 227 | 596 | 381 | 22 | 417 | **2,370** |
| 2 | គោយន្ត | **18,797** | 3,150 | 2,448 | 2,758 | 1,379 | 2,787 | 110 | 4,794 | **17,426** |
| 3 | ម៉ាស៊ីនច្រូតនិងបោកស្រូវ | **216** | 25 | 24 | 15 | 35 | 37 | 3 | 93 | **232** |
| 4 | ម៉ាស៊ីនច្រូតស្រូវ | **366** | 15 | 71 | 5 | 53 | 41 | 12 | 106 | **303** |
| 5 | ម៉ាស៊ីនបោកស្រូវ | **667** | 125 | 44 | 167 | 53 | 103 | 2 | 104 | **598** |
| | សរុប | 21,910 | 3,483 | 2,884 | 3,572 | 1,895 | 4,277 | 174 | 5,625 | 20,929 |

*ប្រប្រភពឯកសារៈឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ចសេដ្ឋកិច្ចសង្គម(ទិន្នន័យមូលដ្ឋានឃុំសង្កាត់ខែធ្នូឆ្នាំ២០២២)*

យោងតាមរូបភាពទី ១១ បង្ហាញថា ស្រុកត្បូងឃ្មុំប្រើប្រាស់គ្រឿងយន្តកសិកកម្មច្រើនជាងគេ បន្ទាប់មកស្រុកពញាក្រែក និងស្រុកមេមត់។ ស្រុកមេមត់ជាស្រុមមួយដែលមានផ្ទៃដីដាំដុះធំ និងគ្រឿងចក្រតិចត្បូងឃ្មុំ និងពញាក្រែក នេះអាចបណ្តាលមកពី ស្រុកមេមត់សំបូរទៅដោយដំណាំរយៈពេលវែង ឬដំណាំកសិឧស្សាហកម្ម និងដំណាំហូបផ្លែច្រើន ដែលជាមូលហេតុកសិករប្រើប្រាស់គ្រឿងចក្រកសិកម្មតិច។ ដោយឡែកសំរាប់

ស្រុកត្បូងឃ្មុំ មានផ្ទៃដីដាំដុះតូច និងគ្រឿងចក្រច្រើនជាងគេដោយហេតុថាស្រុកនេះមានផ្ទៃដីដាំដុះភាគច្រើនជាដំណាំរយៈពេលខ្លី ដែលត្រូវប្រើប្រាស់គ្រឿងចក្រច្រើន។

## ប្រព័ន្ធស្រោចស្រព

ខេត្តត្បូងឃ្មុំមានអាងទឹកសរុប៦៦កន្លែង ទំនប់ទឹកសរុប១២៩កន្លែង និងប្រឡាយទឹកចំនួន១៦០ខ្សែ ដែលអាចស្រោចស្រពបានផ្ទៃដី ៦៥,០៨៨ហិចតា ស្មើនឹង២៣%នៃផ្ទៃដីដាំដុះសរុប ក្នុងឆ្នាំ២០២៣។

*រូបភាពទី ១២ តារាងប្រព័ន្ធធារាសាស្ត្រតាមបណ្ដាក្រុង/ស្រុកឆ្នាំ២០២៣*

| ល.រ | បរិយាយ | ត្បូងឃ្មុំ | ក្រុងសួង | មេមត់ | ពញាក្រែក | តំបែរ | អូររាំងឪ | ក្រូចឆ្មារ | សរុប |
|---|---|---|---|---|---|---|---|---|---|
| 1 | អាងទឹក | 25 | 2 | 1 | 7 | 4 | 22 | 5 | 66 |
| 2 | ទំនប់ទឹក | 32 | | 11 | 11 | 5 | 17 | 53 | 129 |
| 3 | ប្រឡាយទឹក | 47 | 3 | 7 | 26 | 5 | 47 | 25 | 160 |
| 4 | ផ្ទៃដីស្រោចស្របសរុប(ហត) | 6,033 | 278 | 920 | 6,868 | 6,809 | 4,537 | 13,108 | 38,553 |

*ប្រភពឯកសារ:មន្ទីរធនធានទឹកនិងឧត្តុនិយមឆ្នាំ២០២៣*

ស្រុកក្រូចឆ្មារ មានទំហំផ្ទៃដីស្រោចស្រពធំជាងគេសរុប បន្ទាប់មក គឺស្រុកពញាក្រែក និងស្រុកតំបែរ ចំណែកស្រុកដែលមានផ្ទៃដីស្រោចស្រពតូចគឺ ក្រុងសួង និងស្រុកមេមត់។ ស្រុកក្រូចឆ្មារមានសណ្ឋានដី ទំនាបជាប់មាត់ទន្លេ មានភាពងាយស្រួល ក្នុងការរៀបចំប្រព័ន្ធស្រោចស្រព និងមានប្រភពទឹកល្អប្រសើ ដែលជាកត្តាអំណោយផលខាងកសិកម្មដំណាំរយៈពេលខ្លី។

*រូបភាពទី ១៣ ក្រាហ្វិក%ផ្ទៃដីដាំដុះមានប្រព័ន្ធស្រោចស្រព និងទិន្នផលស្រូវឆ្នាំ២០២៣*




*ប្រភពឯកសារ:មន្ទីរធនធានទឹកនិងឧត្តុនិយម,មន្ទីរកសិកម្មរុក្ខាប្រមាញ់និងនេសាទឆ្នាំ២០២៣)*

## ការដាំដុះ

ខេត្តត្បូងឃ្មុំមានផ្ទៃដីដាំដុះសរុប ចំនួន ២២៩,២២២ហិចតា ដំណាំសំខាន់ៗ មានដូចខាងក្រោម៖

- ដំណាំស្រូវ៖ ផ្ទៃដីដាំស្រូវមាន ៨៨,៥៥៥ហិចតា ទិន្នផល៤តោន/ហិចតា។ តាមការប្រៀបធៀប រវាងភាគរយនៃផ្ទៃដីដាំដុះមានប្រព័ន្ធស្រោចស្រព តាមបណ្ដារក្រុង/ស្រុក ជាមួយនឹងទិន្នផលស្រូវតាមបណ្ដាក្រុង/ស្រុក បង្ហាញថាទិន្នផលស្រូវ តាមបណ្ដាក្រុង/ស្រុកមានលក្ខណ:ខុសគ្នា អាស្រ័យលើប្រព័ន្ធស្រោច

ស្រព មានន័យថាក្រុង/ស្រុកណាដែល មានប្រព័ន្ធធារាសាស្ត្រស្រោចស្រពច្រើន នឹងទទួលបានទិន្នផលខ្ពស់ដូចជា ស្រុកត្បូងឃ្មុំ និងក្រូចឆ្មារជាដើម។

- ដំណាំដំឡូងមី៖ មានផ្ទៃដីសរុប ៥២,៨៧៥ហិចតា ទទួលបានទិន្នផលជាមធ្យម ១៧.១៨តោន/ហិចតា។ ដំឡូងមី នៅខេត្តត្បូងឃ្មុំភាគច្រើនដាំដុះនៅ ស្រុកតំបែរ ស្រុកមេមត់ និងស្រុកក្រូចឆ្មារ។
- ដំណាំកៅស៊ូ៖ មានផ្ទៃដីសរុប ១១១,០៧១ហិចតា ទទួលបានទិន្នផលជាមធ្យម ៤.៧៨តោន/ហិចតា។ ដំណាំកៅស៊ូភាគច្រើនមានការដាំដុះនៅតាមបណ្តា ស្រុកមេមត់ ស្រុកពញាក្រែក ស្រុកតំបែរ និងស្រុកត្បូងឃ្មុំ។ ដំណាំប្រភេទនេះទទួលបានទិន្នផលខ្ពស់ សំរាប់ការដាំដុះលើដីក្រហម។
- ដំណាំពោត៖ មានផ្ទៃដីដាំដុះសរុប ១១,៨៣៥ហិចតា ទទួលបានទិន្នផលជាមធ្យម ៦.៣០តោន/ហិចតា។ ដំណាំនេះមានការដាំដុះច្រើននៅ ស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំ ស្ថិតនៅតាមបណ្តោយ ដីសណ្តរទន្លេមេគង្គ។
- ដំណាំស្វាយចន្ទី៖ មានផ្ទៃដីដាំដុះសរុប ៧,៩២០ ហិចតា ទទួលបានទិន្នផលជាមធ្យម ១.៥តោន/ហិចតា។ ដំណាំនេះមានការដាំដុះច្រើននៅតាមបណ្តា ស្រុកតំបែរ មេមត់ ក្រូចឆ្មារ និងពញាក្រែក។
- ដំណាំស្វាយកែវរមៀត៖ មានផ្ទៃដីដាំដុះសរុប ២,២៨៥ ហិចតា ទទួលបានទិន្នផលជាមធ្យម ២៣តោន/ហិចតា។ ដំណាំនេះមានការដាំដុះច្រើននៅតាមបណ្តា ស្រុកតំបែរ ស្រុកត្បូងឃ្មុំ និងស្រុកមេមត់។
- ដំណាំម្រេច៖ មានផ្ទៃដីដាំដុះសរុប ៣,២៧០ហិចតា ទទួលបានទិន្នផលជាមធ្យម ៣.៨៥តោន/ហិចតា។ ដំណាំនេះមានការដាំដុះច្រើននៅ ស្រុកមេមត់ និងស្រុកពញាក្រែក។
- ដំណាំថ្នាំជក់៖ មានផ្ទៃដីដាំដុះសរុប ១,២៣៥ហិចតា ទទួលបានទិន្នផលជាមធ្យម ១.៧៥តោន/ហិចតា។ ដំណាំនេះមានការដាំដុះច្រើននៅ ស្រុកក្រូចឆ្មារ និងស្រុកត្បូងឃ្មុំតាមបណ្តោយដងទន្លេមេគង្គ។
- ដំណាំធុរេន៖ មានផ្ទៃដីដាំដុះសរុប ៨៦០ហិចតា ទទួលបានទិន្នផលជាមធ្យម ១៥.៤តោន/ហិចតា។ ដំណាំនេះមានការដាំដុះច្រើននៅ ស្រុកមេមត់ ស្រុកតំបែរ ស្រុកអូររាំងឪ និងស្រុកពញាក្រែក។

ក្នុងរយៈពេលពីទស្សវត្សកន្លងមកនេះទស្សនៈវិស័យរបស់រដ្ឋាភិបាលកម្ពុជាគឺការធ្វើទំនើបកម្មនៃវិស័យកសិកម្មដោយពឹងផ្អែកទៅលើវិធីសាស្ត្រថ្មី ជាមួយនឹងការផ្លាស់ប្តូរនូវទំហំនិងល្បឿន ក្នុងន័យផ្លាស់ប្តូរវិស័យនេះពីការពឹងផ្អែកយ៉ាងចម្បងទៅលើការប្រើប្រាស់នូវធនធានដែលមានស្រាប់(ធនធានដីនិងធនធានធម្មជាតិដ៏ទៃទៀត) និងធនធានកសិកម្មប្រពៃណី(ប្រើប្រាស់កំលាំងមនុស្ស កំលាំងសត្វ និងឧបករណ៍បុរាណ) ទៅជាការពឹងផ្អែកយ៉ាងចម្បងទៅលើការប្រើប្រាស់បច្ចេកទេស បច្ចេកវិទ្យាថ្មី គ្រឿងយន្ត និងប្រព័ន្ធធារាសាស្ត្រដែលជួយពង្រឹងដល់អត្រាទិន្នផល ក៏ដូចជាពិពិធកម្មទៅលើសកម្មភាពក្នុងផលិតផលដំណាំមានតម្លៃខ្ពស់ ការចិញ្ចឹមសត្វ និងវារីវប្បកម្មជាមួយនឹងការអនុវត្តប្រកបដោយនិរន្តភាពបរិស្ថាន។ ខេត្តត្បូងឃ្មុំក៏មានការផ្លាស់ប្តូរស្របតាមគាមទស្សនៈវិស័យនេះដែល ដោយកសិកភាគច្រើនប្រានផ្លាស់ប្តូរពីការប្រើប្រាស់កំលាំងមនុស្ស មនុស្ស កំលាំងសត្វ និងឧបករណ៍បុរាណ មកប្រើប្រើប្រាស់គ្រឿងយន្ត បច្ចេកទេស និងបច្ចេកវិទ្យាថ្មីៗ។

## ២.៣-សកម្មភាពនៃវិស័យសេវាកម្ម និងកម្មន្តសាល

ខេត្តត្បូងឃ្មុំមាន ក្រុមហ៊ុនចម្ការកៅស៊ូ ក្រុមហ៊ុនកែច្នៃជ័រ និងដើមកៅស៊ូ ក្រុមហ៊ុនចម្ការអំពៅ ក្រុមហ៊ុនកែឆ្នៃដំឡូងមី ក្រុមហ៊ុនសំណង់(កិនថ្ម) ក្រុមហ៊ុននាំចេញម្រេច ក្រុមហ៊ុនម្សៅដំឡូងមី ក្រុមហ៊ុនកែច្នៃសណ្តែកដី ក្រុមហ៊ុនធ្វើទឹបជ័រ ក្រុមហ៊ុនកែច្នៃផ្លែស្វាយកែវរមៀត និងក្រុមហ៊ុនកែឆ្នៃស្វាយចន្ទីជាដើម។

*រូបភាពទី ១៤ %ប្រជាជនមានមុខរបរមិនមែនជាកសិករឆ្នាំ២០២៣*




ផ្អែកលើដង់ស៊ីតេ ប្រជាជនតាមបណ្តាក្រុង/ស្រុក យើងពិនិត្យឃើញថា ក្រុងសួង ស្រុកអូររាំងឪ និងស្រុកត្បូងឃ្មុំ គឺមានដង់ស៊ីតេខ្ពស់ជាងគេ។ បើយោងតាមរូបភាព ទី១៤ ខាងលើយើងសង្កេតឃើញថាប្រជាជនមានមុខរបរមិនមែនកសិកម្មក្នុងខេត្តត្បូងឃ្មុំ មានការប្រមូលផ្តុំច្រើននៅ ក្រុងសួង ស្រុកត្បូងឃ្មុំ និងស្រុកអូររាំងឪ ដែលតាមបណ្តាស្រុកនេះមានការប្រមូលផ្តុំ នូវវិស័យសេវាកម្ម កម្មន្តសាលច្រើនជាងគេ។ ខាងក្រោមនេះជាតារាងស្ថិតិ ទីតាំងសិប្បកម្ម និងសេវាកម្មក្នុងខេត្តត្បូងឃ្មុំឆ្នាំ២០២៣ ដែលមានចំនួនសរុប ១២,០០៩ទីតាំង និងចំនួនបុគ្គលិកបម្រើការងារក្នុងវិស័យនេះសរុប ចំនួន២៩,៨៤០នាក់ ក្នុងនោះ ស្រី១០,៦៨១៣នាក់។

*រូបភពទី ១៥ តារាងចំនួនទីតាំងសិប្បកម្មនិងសេវាកម្មឆ្នាំ២០២៣*



*ប្រភពឯកសារៈឯកសារព័ត៌មានស្ថានភាពស្ដីពីសេដ្ឋកិច្ចសេដ្ឋកិច្ចសង្គម(ទិន្នន័យមូលដ្ឋានឃុំសង្កាត់ខែធ្នូឆ្នាំ២០២៣)*

យោងតាមរូបភាពទី១៤ និងទី១៥ យើងសង្កេតឃើញថា ចំនួនទីតាំងសេវាកម្ម មានការកើនឡើងក្នុងឆ្នាំ២០២០ អាចជាលទ្ធផលពីការគ្រប់គ្រង ការរីករាលដាលជំងឺកូវីដ ១៩បានល្អ។ ចំណែកក្នុងឆ្នាំ២០២១ ការរីករាលដាលនៃជំងឺកូវីដ ១៩ កាន់តែខ្លាំងក្លា បណ្ដាលធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់វិស័យផលិតកម្ម និងវិស័យសេវាកម្មនេះ ដោយឡែកក្នុងឆ្នាំ២០២២ ដល់ឆ្នាំ២០២៣ វិស័យសេវាកម្មនេះបានដំណើរការឡើងវិញយ៉ាងឆាប់រហ័យ។

វិស័យផលិតកម្ម ក៏ទទួលរងនូវឥទ្ធិពលពីជំងឺរាតត្បាតដែរ ប៉ុន្តែមិនសូវមានភាពធ្ងន់ធ្ងរ ដូចជាមានការថយចុះនូវចំនួនទីតាំងសិប្បកម្មចំនួន៦៦៩ទីតាំងនៅឆ្នាំ២០២១ និងមានមានការកើនឡើងដល់ទៅ១,៣៣២ទីតាំងនៅឆ្នាំ២០២៣ ដែលភាគច្រើនជាសិប្បកម្មកិនស្រូវ ផលិតទឹកសុទ្ធ ផលិតគ្រឿងសង្ហារឹម សិប្បកម្មឡូតដ្ឋជាដើម [(2)]។

*រូបភាពទី១៦ ផលធៀបទីតាំងផលិតកម្មនិងសេវាកម្មជាមួយប្រជាជន១០០០នាក់ឆ្នាំ២០២៣*




*ប្រភពឯកសារៈឯកសារព័ត៌មានស្ថានភាពស្ដីពីសេដ្ឋកិច្ចសេដ្ឋកិច្ចសង្គម(ទិន្នន័យមូលដ្ឋានឃុំសង្កាត់ខែធ្នូឆ្នាំ២០២២)*

យោងតាមការធ្វើផលធៀបទីតាំងផលិតកម្ម និងសេវាកម្មជាមួយប្រជាជន១០០០នាក់យើងឃើញថា ក្រុងសួងមានទីតាំងផលិតកម្មខ្ពស់ជាងគេគឺ៧៩ទីតាំងក្នុងប្រជាជន១០០០នាក់ ដោយឡែកស្រុកអូររាំងឪមានទីតាំងផលិតកម្មនិងសេវាកម្មតិចជាងគេគឺមានតែ២៦ទីតាំងប៉ុណ្ណោះក្នុងប្រជាជន១០០០នាក់។ យើងអាចសន្និដ្ឋានបានថានៅតាមបណ្ដាក្រុងស្រុកដែលមានដង់ស៊ីតេខ្ពស់គឺជាបណ្ដុំនូវទីតាំងសេវាកម្ម និងសិប្បកម្ម ដូចជាក្រុងសួង ស្រុកត្បូងឃ្មុំជាដើម។

## ២.៤-វិស័យទេសចរណ៍

ខេត្តត្បូងឃ្មុំ មានទីតាំងរមណីយដ្ឋានចំនួនបីគឺ៖ រមណីយដ្ឋាន វប្បធម៌ប្រវត្តិសាស្ត្រហ្លួងព្រះស្ដេចកន ស្ថិតនៅ ភូមិនគរក្នុង ឃុំដូនតី ស្រុកពញាក្រែក មានចម្ងាយ១៦,៥គីឡូម៉ែត្រ ពីទីរួមខេត្តត្បូងឃ្មុំ តាមផ្លូវជាតិលេខ៧។ ប្រាសាទព្រះធាតុបាស្រី ស្ថិតនៅភូមិព្រះធាតុ ឃុំព្រះធាតុ ស្រុកអូររាំងឪ មានចម្ងាយ៤៣គីឡូម៉ែត្រ ពីទីរួមខេត្តត្បូងឃ្មុំ កាត់ផ្លូវជាតិលេខ១១ បត់ចូលតាមខាងត្បូងផ្សារអូររាំងឪ។ រមណីយដ្ឋាន ទឹកធ្លាក់ហោង ស្ថិតនៅភូមិស្រែវែង ឃុំទឹកជ្រៅ ស្រុកតំបែរ មានចម្ងាយប្រមាណ ៥៧គ.ម ពីទីរួមខេត្តត្បូងឃ្មុំ កាត់តាមផ្លូវជាតិលេខ៧ផ្លូ

[2] ឧប្បសម្ព័ន្ធទី២. តារាងទីតាំងសេវាកកម្មនិងសិប្បកម្មឆ្នាំ២០១៩ដល់ឆ្នាំ២០២៣

របត់ចូលត្រង់ឃុំព្រែក ស្រុកពញាក្រែក។ ក្នុងឆ្នាំ២០២៣ ខេត្តត្បូងឃ្មុំទទួលបានភ្ញៀវជាតិចំនួន ១,២៥០,៨១៩ នាក់ និងភ្ញៀវអន្តរជាតិចំនួណ៥,១៧៤នាក់។

*រូបភាពទី ១៧ តារាងទីតាំងទេសចរតាមបណ្តាក្រុងស្រុកឆ្នាំ២០២៣*

| ល.រ | បរិយាយ | ឯកតា | ២០២២ | ២០២៣ | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | ត្បូងឃ្មុំ | ក្រូចសួច | មេមត់ | ពញាក្រែក | តំបែរ | អូររាំងឪ | ក្រូចឆ្មារ | សរុប |
| 1 | សណ្ឋាគារ | កន្លែង | 5 | 0 | 0 | 2 | 2 | 0 | 1 | 0 | **5** |
| 2 | ផ្ទះសំណាក់ | កន្លែង | 80 | 24 | 5 | 16 | 14 | 2 | 5 | 0 | **66** |
| 3 | មណ្ឌលកំសាន្ត +KTV | កន្លែង | 24 | 24 | 4 | 14 | 5 | 4 | 3 | 0 | **54** |
| 4 | រមណីយដ្ឋាន | កន្លែង | 3 | 1 | 0 | 0 | 0 | 1 | 1 | 0 | **3** |
| សរុប | | | **112** | **49** | **9** | **32** | **21** | **7** | **10** | **0** | **128** |

*ប្រភពឯកសារៈមន្ទីរទេសចរខេត្តត្បូងឃ្មុំឆ្នាំ២០២២*

ក្រៅអំពីទីតាំងខាងលើនេះ ខេត្តត្បូងឃ្មុំក៏មានគោលដៅទេសចរជាច្រើនទៀត ដើម្បីធ្វើការអភិវឌ្ឍអោយក្លាយទៅជាទីតាំងទេសចរបានដែរដូចជាៈ

- សហគមន៍ទេសចរណ៍ ចម្ការឈូករ័ត្ន ទីតាំងនៅភូមិជីពោទ៍ក្រោមទី២ ឃុំជីពោទ៍ទី១ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។
- តួប៉ម តួប៉មនេះគឺជាទីតាំងឆ្នាំទន្លេ ដែលបានសាងសង់ឡើងនៅ សម័យអាណានិគមបារាំង ហើយភ្ញៀវទេសចរអាចមើលឃើញ ទេសភាពនៃក្រុងកំពង់ចាម ក្នុងខេត្តកំពង់ចាម ពីត្រើយខាងកើត នៃទន្លេមេគង្គជាពិសេសនៅពេលថ្ងៃលិច។ តួប៉មនេះស្ថិតនៅភូមិព្រែកតូច ឃុំជីពោទ៍១ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំខាងកើតទន្លេ ទល់មុខនៃទីក្រុងកំពង់ចាម។
- និងសារមន្ទីរបុរាណវិទ្យាមេមត់។

ទីតាំងទីរួមខេត្តត្បូងឃ្មុំ ជាទីតាំងមួយដែលមានភាពធំទូលាយ មានសួនច្បារស្អាតល្អ ដែលអាចអោយរដ្ឋបាលខេត្តរៀបចំព្រឹត្តិការសំខាន់ៗ និងទាក់ទាញជាច្រើនដើម្បីអោយភ្ញៀវជាតិ និងអន្តរជាតិ មកចូលរួមទស្សនាបានកាន់តែច្រើន ដូចជា ព្រឹត្តិការចូលឆ្នាំសាកល ចូលឆ្នាំខ្មែរ បុណ្យអុំទូក និងព្រឹត្តិការតាំងពិព័ណ៌ ប្រគុំតន្ត្រីផ្សេងៗជាច្រើនទៀត។ បើទោះបីជាខេត្តត្បូងឃ្មុំមិនមានលក្ខណៈអំណោយផលខ្លាំងលើវិស័យទេសចរណ៍វប្បធម៌ ធម្មជាតិ ប៉ុន្តែខេត្តត្បូងឃ្មុំនៅតែអាចអភិវឌ្ឍន៍វិស័យទេសចរណ៍របស់ខ្លួនបានតាមរយៈ ការបង្កើតទីតាំងទេសចរណ៍ កែឆ្នៃថ្មីៗ ដូចជាសួនផ្កា អាងហែលទឹក និងមណ្ឌលកំសាន្តផ្សេងៗ។

## ២.៥-វិស័យហិរញ្ញវត្ថុ

### ចំនួនប្រតិបត្តិករវេណទាន

ប្រតិបត្តិករវេណទាន សំដៅលើស្ថាប័នហិរញ្ញវត្ថុឯកជន ដែលបានផ្តល់ជូនសេវាប្រាក់កម្ចី ដល់ប្រជាពលរដ្ឋនៅក្នុងតំបន់ដែលពួកគេរស់នៅផ្ទាល់។ ក្នុងខេត្តត្បូងឃ្មុំមានប្រតិបត្តិករវេណទានសរុប ចំនួន២៦ស្ថាប័ន ក្នុង

នោះធនាគារ មានចំនួន១៦ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន៩ និងក្រុមហ៊ុនភតិសន្យា និងគ្រឹះស្ថានឥនទានជនបទ មានចំនួន១។

*រូបភាពទី ១៨ តារាងចំនួនប្រតិបត្តិករឥណទាន នៅខេត្តត្បូងឃ្មុំឆ្នាំ២០២០ដល់២០២៣*

| ល.រ | ស្ថាប័ន | ២០២២ | ២០២៣ |
|---|---|---|---|
| ១ | ធនាគារ ឬសាខា | ១៤ | ១៦ |
| ៣ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬសាខា | ១០ | ៩ |
| ៤ | ក្រុមហ៊ុនភតិសន្យា និងគ្រឹះស្ថានឥនទានជនបទ | ២ | ១ |

*ប្រភពឯកសារៈរបាយការណ៍ស្តីពីស្ថានភាពឥណទាននៅកម្ពុជាឆ្នាំ២០២២ដល់២០២៣របស់ការិយាល័យឥណទានកម្ពុជា*

ទំនុកចិត្តមកលើប្រព័ន្ធធនាគារក្នុងប្រទេសកម្ពុជាបន្តមានភាពរឹងមាំ បើទោះបីជាឆ្នាំ២០២៣ជាឆ្នាំនៃការបោះឆ្នោត ហើយប្រព័ន្ធធនាគារនៅក្នុងប្រទេសមួយចំនួនបានរងការប៉ះទង្គិចដោយការដួលរលំ នៃគ្រឹះស្ថានធនាគារពាណិជ្ជក៏ដោយ។ ប៉ុន្តែ ការងើបឡើងសន្សឹមៗនៃវិស័យមួយចំនួនបានបណ្តាល ឱ្យកំណើនឥណទានថយចុះមកនៅអត្រាមួយខ្ទង់ជាលើកដំបូងក្នុងរយៈពេលជាង ២សវត្សរ៍ចុងក្រោយនេះ។ ការថយចុះកំណើនឥណទាន គួបផ្សំនឹងការបញ្ចប់ការរៀបចំឥណទានឡើងវិញ ក្នុងអំឡុងវិបត្តិកូវីដ-១៩ បានបណ្តាលឱ្យអនុបាតឥណទានមិនដំណើរការកើនឡើង ដែលតម្រូវឱ្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តបង្កើនការតាមដានវាយតម្លៃជាប់ជាប្រចាំលើហានិភ័យដែលអាចកើតឡើងជាយថាហេតុ។

## ការប្រើប្រាស់ឥណទាន នៅតាមក្រុង/ស្រុក

*រូបភាពទី ១៩ តារាងចំនួនប្រជាជនប្រើប្រាស់ឥណទានតាមបណ្តាក្រុង/ស្រុកឆ្នាំ២០២៣*

| ល.រ | ឈ្មោះក្រុង/ស្រុក | ចំនួនអ្នកខ្ចី | សមតុល្យប្រាក់កម្ចី (លានរៀល) | សមតុល្យប្រាក់កម្ចី /អតិថិជន (លានរៀល) |
|---|---|---|---|---|
| ១ | ក្រូចឆ្មារ | 15,551 | 281,843 | 23 |
| ២ | ត្បូងឃ្មុំ | 46,538 | 1,087,359 | 20 |
| ៣ | តំបែរ | 26,222 | 468,644 | 24 |
| ៤ | ពញាក្រែក | 42,240 | 1,075,003 | 47 |
| ៥ | មេមត់ | 39,362 | 725,870 | 24 |
| ៦ | សួង | 10,294 | 498,619 | 23 |
| ៧ | អូររាំងឪ | 25,434 | 522,854 | 27 |
| | សរុប | **205,641** | **4,660,193** | **22** |

*ប្រភពឯកសារៈរបាយការណ៍ស្តីពីស្ថានភាពឥណទាននៅកម្ពុជាឆ្នាំ២០២២ របស់ការិយាល័យឥណទានកម្ពុជា*

សេវាឥណទានដែលរៀបរាប់ក្នុងរូបភាពទី ១៩ សំដៅលើឥណទានជាលក្ខណៈបុគ្គល ដែលរួមមានឥណទានបង់រំលស់សំភារៈ ប្រើប្រាស់ឥណទានអាជីវកម្មខ្នាតតូច ឥណទានកសិកម្មនិងឥណទានទិញផ្ទះ។ នៅក្នុងខេត្តត្បូងឃ្មុំមានអ្នកប្រើប្រាស់សេវាឥណទានសរុប ចំនួន២០៥,៦៤១នាក់។ សមតុល្យប្រាក់កម្ចីសរុប ដែលប្រជាពលរដ្ឋកំពុងប្រើប្រាស់មានចំនួន ៤,៦៦០,១៩៣លានរៀល ដែលជាមធ្យមអតិថិជនម្នាក់ខ្ចីប្រាក់ចំនួនប្រមាណ ២២លានរៀល។ ក្នុងនោះស្រុកត្បូងឃ្មុំ មានទំហំឥណទានធំជាងគេ ជាមួយលទ្ធភាពខ្ចី ២០លានរៀល

សំរាប់មនុស្សម្នាក់ ខណៈស្រុកពញាក្រែកប្រជាជនមានលទ្ធភាពខ្ចីរហូតដល់ ៨៧លានរៀលសំរាប់មនុស្សម្នាក់ [3]។

*រូបភាពទី ២០ ក្រាហ្វិក%ប្រជាជនគ្រប់អាយុប្រើប្រាស់ឥណទានតាមបណ្តាក្រុង/ស្រុកឆ្នាំ២០២៣*




យោងតាមរូបភាពទី ២០ ខាងលើការប្រើប្រាស់ឥណទានសរុបក្នុងខេត្តត្បូងឃ្មុំមាននិន្នាការកើនឡើងក្នុងឆ្នាំ២០២៣ ចំនួនអ្នកប្រើប្រាស់ឥណទានមានការកើនឡើង ប៉ុន្តែទំហំឥណទានសំរាប់មនុស្សម្នាក់នៅដដែលពោលគឺអ្នកប្រើប្រាស់ឥណទានមិនបានបង្កើនការខ្ចីប្រាក់បន្ថែមនោះទេ។ អត្រាប្រជាជនប្រើប្រាស់ឥណទានក្នុងឆ្នាំ២០២៣ខ្ពស់ជាងគេមានស្រុកអូររាំងឪ និងស្រុកតំបែរ ចំណែកស្រុកក្រូចឆ្មារ ដោយឡែកស្រុកមេមត់មានអត្រាប្រជាជនប្រើប្រាស់ឥណទានតិចជាងគេ។

*រូបភាពទី ២១ %ប្រជាជនមានកម្ចីច្រើនស្ថាប័នឆ្នាំ២០២៣*




[3] ឧបសម្ព័ន្ធទី៣. តារាងសង្ខេបស្តីពីស្ថានភាពឥណទានក្នុងខេត្តត្បូងឃ្មុំ

*ប្រភពឯកសារៈរបាយការណ៍ស្តីពីស្ថានភាពឥណទាននៅកម្ពុជាឆ្នាំ២០២៣របស់ការិយាល័យឥណទានកម្ពុជា*

តាមរយៈរូបភាពទី ២១ ក្រាហ្វិកខាងលើបង្ហាញអោយឃើញថា អ្នកប្រើប្រាស់កម្ចីមួយស្ថាប័នមានចំនួន ៧៧% នៃចំនួនអ្នកប្រើប្រាស់ឥណទានសរុប អ្នកប្រើប្រាស់កម្ចីពីរស្ថាប័នមានចំនួន១៨% និងអ្នកប្រើប្រាស់កម្ចី ៣ស្ថាប័នឡើង មានប្រមាណ ៥% នៃចំនួនអ្នកប្រើប្រាស់ឥណទានសរុប។

*រូបភាពទី ២២ អត្រាឥណទានយឺតក្នុងឆ្នាំ២០២៣*




*ប្រភពឯកសារៈរបាយការណ៍ស្តីពីស្ថានភាពឥណទាននៅកម្ពុជាឆ្នាំ២០២៣របស់ការិយាល័យឥណទានកម្ពុជា*

យោងតាមរូបភាពទី២២ យើងពិនិត្យឃើញថា ក្រុងសួង ស្រុកមេមត់ ត្បូងឃ្មុំ គឺជាតំបន់ដែលមានអត្រាសងយឺតខ្ពស់ ដោយឡែកស្រុកតំបែរ អូររាំងឪ និងស្រុកក្រូចឆ្មារ ជាតំបន់ដែលមានអត្រាសងយឺតទាប។ យើងអាចសន្និដ្ឋានបានថា តំបន់ដែលមានបណ្តុំសេវាកម្ម និងសិប្បកម្មច្រើនតែងមានផលលំបាកក្នុងការសងឥណទានជាងតំបន់ដែលមានរបរកសិកម្មខ្ពស់ ដូចជាតំបែរ និងក្រូចឆ្មារជាដើម ទាំងនេះអាចបណ្តាលមកពីវិស័យសេវាកម្ម និងសិប្បកម្មមិនទាន់ជំណើការល្អឡើងវិញ ខុសពីវិស័យកសិកម្មដែលមានភាពធន់ បូករួមទាំងក្នុងឆ្នាំ២០២៣ តម្លៃទីផ្សារកសិផលមានភាពល្អប្រសើ ហេតុនេះឥណទានយឺតមានអត្រាទាបជាងគេ។

*រូបភាពទី ២៣ អត្រាប្រជាជនប្រើប្រាស់ឥណទានតាមបណ្តារាជធានីខេត្តឆ្នាំ២០២៣*




*ប្រភពឯកសារៈរបាយការណ៍ស្តីពីស្ថានភាពឥណទាននៅកម្ពុជាឆ្នាំ២០២២ របស់ការិយាល័យឥណទានកម្ពុជា*

យោងតាមរូបភាពទី ២៣ បង្ហាញថា ប្រជាជនក្នុងខេត្តត្បូងឃ្មុំមានអាយុលើ១៨ឆ្នាំ ប្រើប្រាស់សេវាឥណទានទាបជាងគេលំដាប់ទី៣ក្នុងឆ្នាំ២០២៣ គឺស្មើ៤៣%នៃប្រជាជនគ្រប់អាយុ លើកលែងតែខេត្តបន្ទាយមានជ័យ និងរាជធានីភ្នំពេញ ។ យោងតាមនិន្នន័យខាងលើយើងអាសន្និដ្ឋានបានថា ប្រជាជនក្នុងខេត្តត្បូងឃ្មុំអាចមានការយល់ដឹងខ្ពស់ក្នុងការប្រើប្រាស់ឥណទាន ឬមានជីវភាពធូរធារដែលអាចមានលទ្ធភាពសងគ្រប់គ្រាន់ ពិសេសគឺប្រើប្រាស់ឥណទានបានត្រឹមត្រូវដោយយកកម្ចីទាំងនោះមកពង្រីកអាជីវកម្មរបស់ខ្លួនជាដើម។

## ២.៦-វិស័យសុខាភិបាល និងអប់រំ

### សុខាភិបាល

ខេត្តត្បូងឃ្មុំមានមន្ទីរពេទ្យចំនួន០៧ ក្នុងនោះមន្ទីរពេទ្យបង្អែកកំរិត១ ចំនួន០១(មន្ទីរពេទ្យបង្អែកតំបែរ) មន្ទីរពេទ្យបង្អែកកំរិត២ ចំនួន០៥ ស្ថិតតាមបណ្តាក្រុង/ស្រុកនីមួយៗ (លើកលែងស្រុកត្បូងឃ្មុំ) និងមន្ទីរពេទ្យខេត្តកំរិត៣ ចំនួន០១ មណ្ឌលសុខភាពចំនួន៧៥ ស្ថិតតាមបណ្តាឃុំសង្កាត់ និងប៉ុស្តិ៍សុខភាពចំនួន០១។ បុគ្គលិកពេទ្យសរុបចំនួន៥៧៩នាក់ ក្នុងនោះវេជ្ជបណ្ឌិតចំនួន១២៣នាក់ គ្រូពេទ្យនិងគិលានុប្បដ្ឋាកចំនួន៤៥៦នាក់ [4]។

[4] ឧប្បសម្ព័ន្ធទី៤. តារាងស្ថិតិទីតាំងផ្តល់សេវាសុខាភិបាលតាមបណ្តាក្រុងស្រុក

*រូបភាពទី ២៤ ផលធៀបចំនួនបុគ្គលិកពេទ្យ នឹងមណ្ឌលសុខភាពតាមបណ្ដាក្រុង/ស្រុកឆ្នាំ២០២៣*




*ប្រភពឯកសារៈមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ*

ក្នុងឆ្នាំ២០២៣ បុគ្គលិកសុខាភិបាលសរុបមានចំនួន១,៣០៥នាក់ កើនឡើងចំនួន១២៥នាក់ ក្នុងនោះបុគ្គលិកបម្រើការងារតាមមណ្ឌលសុខភាពមានចំនួន៦៩១នាក់។ តាមរយៈរូបភាពទី ២៤ បង្ហាញថាស្រុកដែលមានបុគ្គលិកពេទ្យបម្រើការងារនៅមណ្ឌលសុខភាពច្រើនជាងគេ គឺស្រុកពញាក្រែក និងស្រុកអូររាំងឪដោយគិតជាមធ្យមតាមមណ្ឌលសុខភាពនិមួយៗ មានបុគ្គលិកពេទ្យប្រមាណ ១២នាក់ និងស្រុកពញាក្រែកប្រមាណ ១៣នាក់។ ដោយឡែក ស្រុកតំបែរគឺមានបុគ្គលិកពេទ្យតាមមណ្ឌលសុខភាពតិចជាងគេ។

*រូបភាពទី ២៥ ប្រជាជនមកទទួលសេវាសុខាភិបាលនៅតាមបណ្ដាក្រុងស្រុកឆ្នាំ២០២៣*




*ប្រភពឯកសារៈមន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ*

វិស័យសុខាភិបាលខេត្តត្បូងឃ្មុំក្នុងឆ្នាំ២០២៣ ទទួលការពិគ្រោះជំងឺក្រៅសរុបចំនួន៦២៤,២៣២លើក កើនឡើង ៥២,០០៣លើក ស្មើនឹង៩% ទទួលការសម្រាកពេទ្យចំនួន៣១,២៣៩លើក កើនឡើងចំនួន៧,៥៤៧លើក ស្មើនឹង៣២%។ តាមរយៈរូបភាពទី ២៤ និងរូបភាពទី២៥ យើងអាចសន្និដ្ឋានបានថា ក្រុងស្រុកដែលមានបុគ្គលិកពេទ្យតាមមណ្ឌលសុខភាពច្រើន គឺទទួលព្យាបាលអ្នកជំងឺច្រើន ដូចជាពញាក្រែក ត្បូងឃ្មុំ និងក្រុងសួង លើកលែងតែស្រុកអូររាំងឪ។

*រូបភាពទី ២៦ ក្រាហ្វិកចំងាយមធ្យមពីភូមិទៅមណ្ឌលសុខភាព(គ.ម)*




*ប្រភពឯកសារ:ឯកសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ចសេដ្ឋកិច្ចសង្គម(ទិន្នន័យមូលដ្ឋានឃុំសង្កាត់ខែធ្នូឆ្នាំ២០២២)*

តាមរយៈរូបភាពទី២៦ ខាងលើបង្ហាញ ថាស្រុកដែលមានមណ្ឌលសុខភាពនៅឆ្ងាយពីភូមិ គឺស្រុកមេមត់ និងស្រុកពញាក្រែក ចំណែកស្រុកដែលមានមណ្ឌលសុខភាពជិតភូមិជាងគេ គឺស្រុកអូររាំងឪ និងក្រុងសួង។ បើយើងធ្វើការប្រៀបធៀបរូបភាពទី២៤ និង២៥ យើងឃើញថាចំងាយផ្លូវក្នុងស្រុកមេមត់ និងពញាក្រែកឆ្ងាយពីមណ្ឌលសុខភាព ប៉ុន្តែទទួលបានប្រជាជនមកព្យាបាលច្រើនជាងគេចំណែកឯស្រុកដែលមានចំងាយផ្លូវជិតមណ្ឌលសុខភាពទទួលបានប្រជាជនមកព្យាបាលតិចទៅវិញ។ យើងអាចសន្និដ្ឋានបានថាចំងាយពីមណ្ឌលសុខភាពមកភូមិគឺមិនមែនជាកត្តា កំណត់ពីការមកទទួលសេវាសុខាភិបាលនោះទេ។ ស្ថានភាពភូមិសាស្ត្រដែលជាតំបន់ដាច់ស្រយ៉ាល និងមានជីវភាពទាបអាចមានសុខភាពមិនសូវល្អ ដោយឡែកតំបន់ប្រជុំជន មានជីវភាពប្រសើរអាចមានសុខភាពល្អជាង។

## ការអប់រំ

ក្នុងឆ្នាំ២០២៣ខេត្តត្បូងឃ្មុំមានសាលាចំនួន៨១១ ក្នុងនោះសាលាមត្តេយ្យចំនួន៣០៧ សាលាបឋមចំនួន៤០៤ សាលអនុវិទ្យាល័យចំនួន៦៩ និងវិទ្យាល័យចំនួន៣១។ មនុស្សស្ថិតក្នុងវ័យសិក្សាមានចំនួនប្រមាណ ២៨៦,២៣៦នាក់ ក្នុងនោះកុមារកំពុងសិក្សាតាមសាលា ទាំងរដ្ឋនិងឯកជនសរុបចំនួន ២១៦,៨៧៦ នាក់ ស្មើនឹង៨៣% ក្នុងនោះសិស្សមត្តេយ្យសិក្សាមានចំនួន២៨,៨៥១នាក់ សិស្សបឋមសិក្សាមានចំនួន ១០៥,០៣០នាក់ សិស្សអនុវិទ្យាល័យមានចំនួន៥១,០២៩នាក់ និងសិស្សវិទ្យាល័យចំនួន៣១,៩៦៦នាក់[5]។

---

[5] ឧបួសម្ព័ន្ធទី៥. តារាងស្ថិតិសាលារៀន គ្រូបង្រៀន និងសិស្សឆ្នាំ២០២៣

*រូបភាពទី ២៧ ផលធៀបចំនួនសិស្ស និងគ្រូបង្រៀន តាមបណ្តាក្រុង/ស្រុកឆ្នាំ២០២៣*




*ប្រភពឯកសារៈមន្ទីរអប់រំយុវជននិងកីឡាខេត្តត្បូងឃ្មុំ*

ចំនួនសិស្សកំពុងរៀនថ្នាក់បឋមសិក្សា មានចំនួនប្រមាណ១០៩% ធៀបនឹងកុមារមានអាយុចន្លោះ៦-១១ឆ្នាំ អត្រាលើសរបស់សិស្សថ្នាក់បឋមសិក្សាអាចបណ្តាលមកពីការចូលរៀនយឺត ក្នុងកំឡុងពេលវិបត្តិរីករាលដាលជំងឺCovid-19 ដោយសារកុមារគ្រប់អាយុចូលរៀនមួយចំនួនមិនបានចូលរៀន ហេតុនេះធ្វើអោយពួកគាត់មិនអាចបញ្ចប់ថ្នាក់បឋមសិក្សាក្នុងអាយុ១១ ឬ១២ឆ្នាំបាន។ ចំនួនសិស្សកំពុងរៀនថ្នាក់អនុវិទ្យាល័យមានចំនួនប្រមាណ៩៥% ធៀបនឹងកុមារមានអាយុចន្លោះ១២-១៤ឆ្នាំ ដោយឡែកចំនួនសិស្សកំពុងរៀនថ្នាក់វិទ្យាល័យមានចំនួនប្រមាណ៥៧% ធៀបនឹងប្រជាជនមានអាយុចន្លោះ១៥-១៧ឆ្នាំ[(6)]។ កត្តាសិស្សនៅថ្នាក់វិទ្យាល័យមានចំនួនតិច(៥៧%) អាចបណ្តាលមកពីការបោះបង់ការសិក្សាបន្ទាប់ពីបញ្ចប់ថ្នាក់អនុវិទ្យាល័យ។ ចំពោះចំនួនសិស្សខុសគ្នាខ្លាំង រវាងសិស្សថ្នាក់បឋមសិក្សា និងសិស្សអនុវិទ្យាល័យ អាចជាកត្តាមួយដែលសិស្សត្រូវបោះបង់ការសិក្សាត្រឹមថ្នាក់បឋមសិក្សាដោយមូលហេតុផ្សេងៗ។ យោងតាមរូបភាពទី ២៧ ខាងលើ បង្ហាញថា ផលធៀបរវាងចំនួនសិស្ស និងគ្រូនៅបឋមសិក្សា មិនមានភាពសមស្រប ជាពិសេសគ្រូ និងសិស្សថ្នាក់មត្តេយ្យសិក្សា។

ចំពោះបញ្ហាប្រឈមមួយចំនួនក្នុងវិស័យនេះមានដូចជា៖ ហេដ្ឋារចនាសម្ព័ន្ធមត្តេយ្យសិក្សាពុំទាន់ឆ្លើយតបស្តង់ដាសេវា និងតម្រូវការពង្រីកសេវាអប់រំកុមារតូច, ខ្វះគ្រូបង្រៀននៅតាមគ្រឹះស្ថានសិក្សាមួយចំនួន, អគារសិក្សាមួយចំនួនចាស់ទ្រុឌទ្រោមប្រើប្រាស់មិនបាន, សិស្សទទួលបានអាហារូបករណ៍នៅតែប្រឈមនឹងការបោះបង់ការសិក្សា, ខ្វះបណ្ណាល័យបន្ទប់ពិសោធន៍, មានការលំបាកក្នុងការប្រមូលសិស្សអប់រំក្រៅប្រព័ន្ធ, ការចូលរួមពីអាជ្ញាធរមូលដ្ឋានមិនទាន់បានទូលំទូលាយជាដើម។

---

[6] ឧបសម្ព័ន្ធទី៥. តារាងស្ថិតិសាលារៀន គ្រូបង្រៀន និងសិស្សឆ្នាំ២០២៣

*រូបភាពទី ២៨ ចំងាយមធ្យមពីកណ្ដាលភូមិទៅសាលា(គ.ម)*




*ប្រភពឯកសារ:ឯកសារព័ត៌មានស្ថានភាពស្ដីពីសេដ្ឋកិច្ចសេដ្ឋកិច្ចសង្គម(ទិន្ន័យមូលដ្ឋានឃុំសង្កាត់ខែធ្នូឆ្នាំ២០១៩)*

តាមរយៈរូបភាពទី២៨ ក្រាហ្វិកខាងលើយើងឃើញថា ចំងាយផ្លូវជាមធ្យម ពីកណ្ដាលភូមិ ទៅសាលាក្នុងស្រុកមេមត់ គឺមានចំងាយផ្លូវឆ្ងាយជាងគេ គិតជាមធ្យម១៧.២គីឡូម៉ែត្រ បន្ទាប់មក គឺស្រុកតំបែរ មានចំង៉ាយផ្លូវជាមធ្យម ១៣.៥គីឡូម៉ែត្រ និងស្រុកពញាក្រែកមានចំងាយផ្លូវជាមធ្យម ១០.១គីឡូម៉ែត្រ។ ម្យ៉ាងទៀតយើងពិនិត្យឃើញថា ចំងាយផ្លូវកាន់តែឆ្ងាយនៅពេលដែលសិស្សបន្តការសិក្សាកាន់តែខ្ពស់ ពោលគឺថ្នាក់វិទ្យាល័យ ប្រការនេះអាចជាមូលហេតុមួយក្នុងចំណោមច្រើន ដែលសិស្សថ្នាក់វិទ្យាល័យមានចំនួនកាន់តែតិចជាងសិស្សថ្នាក់អនុវិទ្យាល័យ និងបឋមសិក្សា។

អត្រាកុមារបោះបង់ការសិក្សាខ្ពស់នៅថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ ជាកត្តាមួយដែលគួរអោយមានការយកចិត្តទុកដាក់ខ្ពស់ ព្រោះថានៅថ្ងៃអនាគត កុមារដែលបោះបង់ការសិក្សាទាំងនោះអាចនឹង ពិបាកក្នុងការស្វែងរកការងារ និងវិជ្ជាជីវសំរាប់ពួកគេ ដែលអាចនឹងធ្វើអោយផែនការអភិវឌ្ឍន៍ធនធានមនុស្ស ជួបនឹងឧប្បស័កច្រើន។

## ៣- ការវិភាគភាពខ្លាំង ( Strengths )ភាពខ្សោយ ( Weakness ) ឱកាស ( Opportunities ) និងការគំរាមកំហែង ( Threats )

SWOT គឺជាអក្សរកាត់ដែល អក្សរនីមួយៗ តំណាងឱ្យ (Strengths) ភាពខ្លាំង (Weaknesses) ភាពខ្សោយ (Opportunities) ឱកាស (Threats) ការគំរាមកំហែង។ ការវិភាគSWOT អាចយកមកប្រើប្រាស់ ដើម្បីកំណត់ និងវិភាគភាពខ្លាំង ភាពខ្សោយ ក៏ដូចជា ឱកាស និងការគំរាមកំហែង របស់ស្ថាប័នគ្រឹះស្ថាន ឬអង្គភាពដោយធ្វើការប្រមូលពត៌មាននានា នៅមជ្ឈដ្ឋានខាងក្រៅ និងមជ្ឈដ្ឋានខាងក្នុងរបស់អង្គភាព។ ការវិភាគSWOT ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីកសាងផែនការយុទ្ធសាស្ត្រមួយ ដែលមានការគិតគូរទៅលើ កត្តាខាងក្នុង និងខាងក្រៅ និងដើម្បីធ្វើឱ្យក្លាយជាអតិបរិមា នូវសក្ដានុពល នៃភាពខ្លាំង និងឱកាស ដោយកាត់បន្ថយអោយបានជា អប្បបរិមានូវភាពខ្សោយ និងការគំរាមកំហែង។ ទីបញ្ចប់នៃការវិភាគSWOT គឺជាអនុសាសន៍ និងការណែនាំឱ្យអនុវត្តដែលជាមូលដ្ឋានគ្រឹះក្នុងការរៀបចំនូវផែនការផ្សេងៗទៀតជាបន្តបន្ទាប់។

SWOT ត្រូវបានគេអភិវឌ្ឍន៍ ក្នុងភាពសាមញ្ញ ក៏ប៉ុន្តែមានប្រសិទ្ធិភាពសំរាប់ការវិភាគ នៅក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្រ្ត ផែនការយុទ្ធវិធី និងផែកការអនុវត្តជាដើម។ ក៏ប៉ុន្តែនៅក្នុងដំណើរការនេះការវិភាគ SWOT មិនមែនជាជំហានដំបូង ឬចុងក្រោយបំផុតនោះទេ វាពឹងពាក់អាស្រ័យទៅលើព័ត៌មាន និងចំណេះដឹងគ្រប់គ្រាន់អំពីមជ្ឈដ្ឋានរបស់អង្គភាព និងទំនោរនានាក៏ដូចជាធនធានខាងក្នុងដែរ។ SWOT ជាទូរទៅត្រូវបានប្រើប្រាស់ក្នុងការវិភាគលើស្ថានភាពអាជីវកម្មជំនួញក្នុងវិស័យឯកជន ដែលជាធម្មតាតែងតែកំណត់យកមូលដ្ឋាន នៃបទពិសោធន៍ពីអតីតកាល ហើយកំណត់ទិសដៅសកម្មភាព ទៅតាមនិយមន័យច្បាស់លាស់ នៃចំណែកទីផ្សារ និងតំបន់ តម្រូវការរបស់អតិថិជនជាដើម។ល។

## ៣.១-ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង

### ភាពខ្លាំង Strengths

1. មានលក្ខណៈអំណោយផលលើដំណាំគ្រប់ប្រភេទ ពិសេសប្រភេទដំណាំកសិឧស្សាហកម្ម
   - ដំណាំកៅស៊ូលក្ខណៈគ្រួសារ មានផ្ទៃដីដាំដុះសរុប ១១១,០៧១ហិចតាទិន្នផលជាមធ្យម ៤.៧៨តោន/ហ.ត ផលជាមធ្យម ៥៣០,៩១៩តោន/ឆ្នាំ។ ផលិតផលដែលត្រូវ ផលិតចេញពីជ័រកៅស៊ូក្នុងស្រុក មានដូចជា៖ សំបកកង់រថយន្ត, ពូក, ស្បែកជើង និងទ្រនាប់បាតស្បែកជើងឃ្លុប, ធុងសំរាម, ស៊ីមទ្វា និងស៊ីមបង្អួចកញ្ចក់គ្រប់ប្រភេទ, ពុម្ពគ្រប់ប្រភេទសម្រាប់ ធ្វើជាពុម្ពផលិតតដួ, រ៉ងនិងវិញគ្រប់ប្រភេទ ទុយោ កៅស៊ូទន់គ្រប់ប្រភេទ។ល។ ការកែច្នៃជាផលិតផល

*រូបភាពទី ២៩ ផលិតផលពីជ័រកៅស៊ូធម្មជាតិ*



សំរេច ឬពាក់កណ្តាលសំរេចទាំងនេះ ហើយដែលជាកត្តាធ្វើអោយតម្លៃជ័រកៅស៊ូ កើនតម្លៃខ្ពស់ឡើងវិញ និងអាចបង្កើតការងារបន្ថែមទៀតដល់ពលរដ្ឋក្នុងស្រុក។ បច្ចុប្បន្ននេះ មានក្រុមហ៊ុនក្នុងស្រុកមួយចំនួនបានបើកដំណើការរោងចក្រផលិតសំបកកង់ ដើម្បីប្រើប្រាស់ក្នុងស្រុក និងធ្វើការនាំចេញ ដោយឡែកសំរាប់ខេត្តត្បូងឃ្មុំ មានតែផលិតផលជ័រកៅស៊ូប្រមាណ ២០%ដែលផ្គត់ផ្គង់ទីផ្សារក្នុងស្រុក នៅសល់ប្រមាណ៨០%នៃផលិតផលជ័រកៅស៊ូត្រូវបាននាំចេញទៅប្រទេសវៀតណាម ដោយមិនមានការកែឆ្នៃឡើយ។

- ដំណាំស្វាយចន្ទី៖ មានផ្ទៃដីដាំដុះសរុប ៧,៩២០ហិចតា ទិន្នផលមធ្យម ១.៥តោន/ហ.ត ដែលទិន្នផលសរុបប្រចាំឆ្នាំជាមធ្យម ១១,៨៥០តោន។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ ប្រជាជនក្នុងស្រុកនិយម បរិភោគគ្រាប់ស្វាយចន្ទីដោយសារគ្រាប់ធញ្ញជាតិនេះមានរស់ជាតិឆ្ងុយឆ្ងាញ់ និងអាចកែឆ្នៃរស់ជាតិតាមចំណង់ចំណូលចិត្តបានដោយលីង ឬបំពង និងដាក់បន្ថែមរស់ជាតិផ្សេងៗតាមចំណូលចិត្ត។ ចំពោះគ្រាប់ស្វាយចន្ទីទាំងមូល និងបែក គឺមានតម្លៃខុសគ្នានៅលើទីផ្សារ។ ម្យ៉ាងទៀត គេអាចយកទៅផ្សំជាមួយគ្រាប់រុក្ខជាតិ ឬផ្លែឈើក្រៀមដទៃទៀតសម្រាប់អាហារសម្រន់ និងក្នុងពិធីជប់លៀងផ្សេងៗផងដែរ។ នៅអាមេរិកខាងជើង និងអឺរ៉ុបមានប្រជាជនចូលចិត្តបរិភោគ គ្រាប់ស្វាយចន្ទីច្រើនជាងគេលើពិភពលោក។ បច្ចុប្បន្នគ្រាប់ស្វាយចន្ទីទើបតែត្រូវបានបញ្ចូល ទៅក្នុងអាហារជួយបំប៉នសុខភាព។ ជាទូរទៅផលិតផល ពី

*រូបភាពទី ៣០ ការកែច្នៃគ្រាប់ស្វាយចន្ទី*



គ្រាប់ស្វាយចន្ទីមាន៖ គ្រាប់ស្វាយចន្ទីប្រភេទធម្មតាស្វាយចន្ទីលីង និងប្រឡាក់អំបិល(មូល

ឬពាក់កណ្តាល ឬជាបំណែកៗ) គ្រាប់ស្វាយចន្ទីសរីរាង្គ គ្រាប់យចន្ទីឆៅ(មូលឬ បំបែកជាបំណែក) ជាដើម។ ម៉្យាងទៀតគេនៅអាចយកគ្រាប់ស្វាយចន្ទីទៅប្រើប្រាស់ ក្នុងសិប្បកម្មដុតនំ ដោយប្រើគ្រាប់ចន្ទីធ្វើជាស្នូលនំ អាចជួយអោយនំមានរស់ជាតិឈ្ងុយឆ្ងាញ់។ បច្ចុប្បន្ននេះការនិយមបរិភោគគ្រាប់ស្វាយចន្ទី កាត់តែមានការកើនឡើងជាលំដាប់ ទូរទាំងពិភពលោក និងក្នុងស្រុក។

- ដំណាំដំឡូងមីៈ ផ្ទៃដីដាំដុះសរុប ៥២,៨៧៥ហិចតា ទិន្នផលជាមធ្យម ១៧.១៨តោន/ហ.ត ទិន្នផលប្រចាំឆ្នាំជាមធ្យម ៩០៨,៣៩២តោន។ ទីផ្សារអន្តរជាតិ មានឥទ្ធិពលលើតម្រូវការដំឡូងមីក្នុងប្រទេសកម្ពុជា។ ការកែច្នៃដំឡូងមីនៅក្នុងប្រទេសកម្ពុជាមានបីប្រភេទរួមមានៈ បន្ទះដំឡូងមីស្ងួត ម្សៅស្ងួត និងម្សៅសើម។ ដោយសារតែដំឡូងមី សំបូរសារធាតុ កាបូអ៊ីដ្រាត ហេតុនេះដំឡូងមី គឺជាដំណាំដ៏មានសក្តានុពល ក្នុងការផលិតអេតាណុល ជីវឥន្ធនៈ និងផលិតផលម្សៅមូលដ្ឋានដទៃៗទៀតដោយរួមមានៈ ប៊ីចេង ថ្នាំពេទ្យ និងសារធាតុប្លាស្ទិកជាដើម។
- ដំណាំម្រេចៈ ផ្ទៃដីដាំដុះសរុប ៣,២៧០ហិចតា ទិន្នផលជាមធ្យម៣.៨៥តោន/ហ.តទិន្នផលប្រចាំឆ្នាំជាមធ្យម១២,៥៨៩តោន។ យោងតាមទិន្នន័យសមាគមម្រេច បង្ហាញថាកម្ពុជាបាននាំចេញម្រេចទៅគោលដៅចំនួន ១៦ ប្រទេសទាំងទ្វីបអាស៊ី និងអឺរ៉ុប ក្នុងនោះប្រទេសវៀតណាម ជាទីផ្សារម្រេចឈានមុខគេ និងតាមពីក្រោយដោយទីផ្សាររបស់ប្រទេសអាល្លឺម៉ង់ ក្រៅពីនេះរួមមានប្រទេសបែលហ្សិក កាណាដា ឆែក បារាំង ឥណ្ឌា ជប៉ុន កូរ៉េ ប៉ូឡូញ រុស្ស៊ី ស៊ុយអែត ស្វ៊ីស កោះតៃវ៉ាន់ អង់គ្លេស អារ៉ាប់ និងអាមេរិក។

*រូបភាពទី ៣១ ដំណាំម្រេច*



- ដំណាំធុរេន៖ មានផ្ទៃដីដាំដុះសរុប ៨៦០ហិចតា ទិន្នផលជាមធ្យម ១៥,៤តោន/ហ.ត ទិន្នផលប្រចាំឆ្នាំជាមធ្យម ១៣,២៤៤តោន។ ធុរេនត្រូវបានគេចាត់ទុកជាប្រភេទ ផ្លែឈើដែឡតម្លៃខ្ពស់ ដែលទទួលបានការពេញនិយម ជាខ្លាំងពីសំណាក់ប្រជាជននៅក្នុងប្រទេស និងក្នុងតំបន់អាស៊ីព្រោះថាផ្លែឈើប្រភេទនេះ មិនត្រឹមតែមានរសជាតិឆ្ងាញ់ ខុសគេនោះទេ វាថែមទាំងមានក្លិនដែលមិនអាចលាក់បាំងពីច្រមុះអ្នកដទៃទៀតផង។ បច្ចុប្បន្ន តម្រូវការធុរេនក្នុងស្រុកមានការ កើនឡើងដោយហេតុថាធុរេន ដែលដាំដុះក្នុងប្រទេសកម្ពុជាមានរស់ជាតិឆ្ងាញ់ ជាងធុរេននាំចូល ពីប្រទេសជិតខាង រីឯតម្លៃវិញក៍ខ្ពស់ជាងដែរ។

2. វិស័យពាណិជ្ជកម្ម៖ ខេត្តត្បូងឃ្មុំ ជាខេត្តជាប់ព្រំដែន ជាមួយប្រទេសវៀតណាម មានច្រកព្រំដែនអន្តរជាតិចំនួន១ ច្រកទ្វេភាគីចំនួន២ និងច្រករបៀងចំនួន៤។ ទំហំពាណិជ្ជកម្មក្នុងឆ្នាំ២០២៣សរុបរបស់ខេត្តជាមួយ ប្រទេសវៀតណាម រួមមានទំនិញនាំចេញមានចំនួនប្រមាណ ១៦៩.៥លានដុល្លារអាមេរិក និងទំនិញនាំចូលប្រមាណ ១០៥.៨លានដុល្លារអាមេរិក។ អតិរេកនេះបង្ហាញថាខេត្តត្បូងឃ្មុំ មានការនាំចេញច្រើន ដែលភាគច្រើនជាប្រភេទទំនិញ កសិផល ឬកសិផលកែឆ្នៃពាក់កណ្តាលសំរេច ដូចជា ស្វាយ ស្វាយចន្ទី ម្រេច ដំឡូងមី ស្រូវ និងពោតជាដើម។
3. កំលាំងពលកម្មច្រើន៖ ប្រជាជនក្នុងខេត្តត្បូងឃ្មុំ ដែលមានអាយុ ១៨ ដល់៦០ឆ្នាំ មានប្រមាណ ៥៥.៦៩% នៃប្រជាជនសរុប នេះជាអត្រាមួយខ្ពស់ រួមជាមួយដង់ស៊ីតេប្រជាជនខ្ពស់ ជាពិសេសក្រុងសួង ស្រុកអូររាំងឪ និងស្រុកត្បូងឃ្មុំ ដែលជាហេតុធ្វើអោយខេត្តត្បូងឃ្មុំ មានសក្តានុពលខ្លាំងក្នុងការផ្គត់ផ្គង កំលាំងពលកម្ម ដែលអាចឆ្លើយតប នឹងតម្រូវការក្នុងវិស័យសេវាកម្ម សិប្បកម្ម និងឧស្សាហកម្មបាន។
4. ប្រជាជនមានជីវភាពមធ្យមច្រើន យោងតាមផលិតផលស្រុកសរុបសំរាប់មនុស្សម្នាក់របស់ខេត្តត្បូងឃ្មុំស្មើ ១,៥៩៧$ក្នុងឆ្នាំ២០២២ និងអត្រាអ្នកប្រើប្រាស់ឥណទានទាបស្មើ ៤៣%នៃប្រជាជនគ្រប់អាយុ ដែលជាតួរលេខទាបជាងគេលំដាប់ទីបីក្នុងប្រទេស ឬអាចនិយាយម្យ៉ាងទៀតថាប្រជាជនមានលទ្ធភាពសងគ្រប់គ្រាន់ និងចេះប្រើប្រាស់នូវកម្ចីទាំងនោះបានចំគោលដៅ និងត្រឹមត្រូវល្អ។

**ភាពខ្សោយ** Weaknesses

1. ខ្វះការវិនិយោគ លើការកែច្នៃកសិផលក្នុងស្រុកមុននឹងធ្វើការនាំចេញដូចជា កៅស៊ូ ស្វាយចន្ទី ដំឡូងមីជាដើម។ បច្ចុប្បន្ន ការនាំចេញកសិផល ដែលមិនទាន់មានការកែច្នៃទៅ ប្រទេសវៀតណាម មានចំនួនច្រើនដែលជាហេតុធ្វើអោយកសិករទទួលបានប្រាក់ចំនេញទាប មិនអាចបង្កើតការងារបន្ថែមក្នុងស្រុកបាន និងមិនអាចទាញយកតម្លៃបន្ថែមពីការកែច្នៃកសិផលក្នុងស្រុក។
2. មិនមានលក្ខណៈអំណោយផលលើវិស័យទេសចរណ៍ ដោយហេតុថាភូមិសាស្ត្រខេត្ត មិនសំបូរទីទាំងវប្បធម៌ និងទីតាំងធម្មជាតិដែលមានភាពទាក់ទាញ។

3. តម្លៃអគ្គិសនីនៅមានតម្លៃខ្ពស់ បើធៀបប្រទេសជិតខាង(ប្រមាណ ៧០០រៀល/KW)។ បច្ចុប្បន្នកត្តាថាមពលពិសេស អគ្គិសនី និងឥន្ធនៈ ជាចំណាយផលិតកម្មមួយយ៉ាងសំខាន់ដែល អ្នកវិនិយោគក្នុងវិស័យ ផលិតកម្មនានាចាំបាច់ត្រូវយកចិត្តទុកដាក់ និងពិចារណា។
4. ប្រព័ន្ធសុខាភិបាល និងអប់រំនៅមានកំរិតៈ ប្រជាជនកមទទួលសេវាសុខាភិបាលនៅតាមមណ្ឌលសុខភាព មានចំនួនតិច នេះបើយើងធ្វើការប្រៀបធៀប ចំនួនប្រជាជនមកទទួលការព្យាបាល និងចំនួនគ្រូពេទ្យនៅតាមបណ្តាក្រុង/ស្រុក។ អត្រាកុមារបោះបង់ការសិក្សានៅថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យមានកំតិតខ្ពស់។

## ឱកាស Opportunities

1. ជាខេត្តជាប់ព្រំដែន មានអតិរេកជញ្ជីងពាណិជ្ជកម្មជាមួយ ប្រទេសវៀតណាម ដែលមានសក្តានុពលខ្ពស់ក្នុការនាំចេញ។
2. តម្រូវការទីផ្សារខ្ពស់សំរាប់កសិផលមួយចំនួនដូចជាៈ ជ័រកៅស៊ូ ស្រូវ ដំឡូងមី ពោត គ្រាប់ស្វាយចន្ទី ធុរេន ម្រេច ថ្នាំជន់ជាដើម។ ក្នុងស្ថានភាពនយោបាយពិភពលោកមិនមានភាពប្រាកដនិយម ជាពិសេសសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងភាពតានតឹងនៅមជ្ឈិបបូព៌ា រួមទាំងកំណើនមនុស្សជាតិ បានធ្វើអោយតម្រូវការ សំភារៈចាំបាច់ប្រើប្រាស់ប្រចាំថ្ងៃ និងស្បៀងអាហារលើទីផ្សារអន្តរជាតិនៅតែបន្តកើនឡើង។
3. កម្ពុជា មានកិច្ចសហប្រតិបត្តិការ ផ្នែកពាណិជ្ជកម្មល្អ ជាមួយប្រទេសក្នុងតំបន់ និងលើពិភពលោក។
4. និន្នាការកើនឡើងនូវ តម្រូវការស្បៀងអាហារ និងគ្រឿងទេស ដែលមានស្តង់ដាសុវត្ថិភាពខ្ពស់នៅលើពិភពលោក មានការកើឡើងជាលំដាប់ ស្របពេលជាមួយគ្នានេះ កម្ពុជាកំពុងតែអភិវឌ្ឍន៍វិស័យកសិកម្ម របស់ខ្លួនដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារក្នុងស្រុក និងសាកលលោក។ បច្ចុប្បន្នអ្នកប្រើប្រាស់អ្នកក្នុងស្រុក និងក្រៅស្រុក តែងតែងគិតជាចម្បងទៅលើសុវត្ថិភាពម្ហូបអាហារដែលជាមូលដ្ឋានគ្រឹះក្នុងការថែរក្សាសុខភាព ហេតុនេះនិន្នាការនៃការនិយមបរិភោគអាហារដែលគ្មានជាតិគីមី រឺប្រើប្រាស់សារធាតុគីមីបានត្រឹមត្រូវ ដែលហៅថា“*អាហារសរីរាង្គ*” ត្រូវបានកើនឡើងទាំង ក្នុងស្រុក និងក្រៅស្រុក។





## ការគំរាមកំហែងThreats

1. ភាពមិនប្រាកដនិយម នៃសេដ្ឋកិច្ច និងនយោបាយពិភពលោកជាពិសេសឥទ្ធិពល សង្គ្រាមពាណិជ្ជកម្មរបស់មហាអំណាចលើសេដ្ឋកិច្ចពិភពលោកដែលជាកត្តា ធ្វើអោយប៉ះពាល់ដល់តម្រូវការទីផ្សារ របស់កម្ពុជា។ សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងការដាក់ទណ្ឌកម្មសេដ្ឋកិច្ច បានធ្វើអោយប៉ះពាល់ដល់សេដ្ឋកិច្ច កម្ពុជាផងដែរ។
2. អតិផរណាខ្ពស់ លើតម្លៃទំនិញមួយចំនួន ជាពិសេសតម្លៃប្រេងឥន្ធនៈអន្តរជាតិ អត្រាប្តូរប្រាក់ដុល្លារ។
3. ទីផ្សារពលកម្ម និងលក្ខ័ណ្ឌផ្សេងៗទៀត របស់ប្រទេសជិតខាង ក៏ជាកត្តាមួយដែលអាចទាក់ទាញវិនិយោគិនបរទេសអោយងាកចេញពីកម្ពុជា។
4. ការប្រែប្រួលអាសធាតុគឺជា បញ្ហាប្រឈមមួយ ដែលមានឥទ្ធិពលលើទិន្នផលកសិកម្មរបស់កម្ពុជា។
5. ការអនុលោមតាមស្តង់ដារអន្តរជាតិ សំរាប់ផលិតផលដែលត្រូវនាំចេញនៅលើទីផ្សារអន្តរជាតិជាបញ្ហាមួយដែលតម្រូវឱ្យកម្ពុជាត្រូវអនុលោមតាម។



## ៣.២-ការវិភាគខ្វែងគ្នារវាងភាពខ្លាំងភាពខ្សោយឱកាសនិងការគំរាមកំហែង

| **ភាពខ្លាំង**(S) : | **ភាពខ្សោយ**(W): |
|---|---|
| ១-មានសក្តានុពលដំណាំកសិឧស្សាហកម្ម និងដំណាំផ្សេងៗ<br>២-កំលាំងពលកម្មច្រើន ប្រជាជនអាយុ ១៨-៦០ ឆ្នាំមាន ៥៥%, ដង់ស៊ីតេខ្ពស់<br>៣-មានសក្តានុពលផ្នែកពាណិជ្ជកម្ម នាំចេញ | ១- ខ្វះការកែច្នៃកសិផល ទៅជាផលិតផលសំរេច (ខ្វះការវិនិយោគ)<br>២-មិនមានលក្ខណៈអំណោយផលលើវិស័យទេសចរណ៍<br>៣-តម្លៃថាមពលខ្ពស់សំរាប់វិស័យឧស្សាហកម្ម |
| **ឱកាស**(O):<br>១-តម្រូវការវត្ថុធាតុដើមក្នុងវិស័យឧស្សាហកម្ម<br>២-មានកិច្ចសហប្រតិបត្តិការល្អជាមួយប្រទេសដៃគូ<br>៣-តម្រូវការផលិតផលនិងអាហារមានសុវត្ថិភាព | **ការគំរាមកំហែង**(T):<br>១-ភាពមិនប្រាកដនិយមនៃសេដ្ឋកិច្ចនយោបាយពិភពលោក<br>២-អតិផរណាសាលក លើទំនិញសំខាន់ៗ<br>៣-ការប្រែប្រួលអាកាសធាតុ |

**ខេត្តត្បូងឃ្មុំ**

តាមរយៈម៉ាទ្រីស SWOT ខាងលើយើងអាចទទួលបាននូវ ជម្រើសដូចខាងក្រោម៖

- រវាងភាពខ្លាំង(Strength) និងឱកាស(Opportunities)៖ បន្តអភិវឌ្ឍន៍លើវិស័យកសិកម្មពីកសកម្មបែបប្រពៃណី ទៅជាកសិកម្មបែបទំនើប ពិសេសត្រូវជំរុញ និងលើកទឹកចិត្តដល់កសិករអោយពួកគាត់សិក្សាស្វែងយល់បន្ថែមលើជំនាញដែលមានស្រាប់ ដើម្បីបង្កើនទិន្នផលរបស់គាត់ប្រកបដោយចិរភាព (ដូចជាការប្រើប្រាស់បច្ចេកទេស ការប្រើប្រាស់ជីធម្មជាតិ ជីគីមី ការរៀបចំដី និងការរៀបចំប្រព័ន្ធស្រោចស្រពជាដើម)។ ម្យ៉ាងទៀតដើម្បីឆ្លើយតបតាមតម្រូវការទីផ្សារ រាល់ផលិតផលទាំងអស់ត្រូវព្យាយាមធ្វើយ៉ាងណា ត្រូវអនុលោមតាមស្តង់ដារដែលបានកំណត់ទាំងក្នុងស្រុក និងក្រៅស្រុក។ បង្កើនការនាំចេញផលិតផលសំរេច និងពាក់កណ្តាលសំរេចទៅប្រទេសជាដៃគូរពាណិជ្ជកម្ម និងប្រទេសជិតខាង អោយបានកាន់តែច្រើន។ អភិវឌ្ឍន៍កំលាំងពលកម្ម ពិសេសកំលាំងយុវជន អោយក្លាយទៅជាកំលាំងពលកម្មដែលមាន ជំនាញវិជ្ជាជីវៈ និងមានផលិតភាពផលិតកម្មខ្ពស់ គឺជាកត្តាសំខាន់ក្នុងការទាក់ទាញអ្នកវិនិយោគក្នុង និងក្រៅប្រទេស។

  បង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ដល់យុវជននៅមូលដ្ឋាន ពិសេសលើយុវជន ដែលមានកំរិតសិក្សាក្រោមថ្នាក់ទី១២ ដើម្បីក្លាយទៅជាកំលាំងពលកម្មជំនាញ។ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនេះត្រូវផ្តោតសំខាន់ទៅលើ ជំនាញវិជ្ជាជីវៈ ណាដែលមានតម្រូវការ និងបម្រើអោយទីផ្សារការងារក្នុងតំបន់ដោយផ្ទាល់។

- រវាងភាពខ្លាំង (Strength) និងការគំរាមកំហែង(Threats)៖ ការចុះកិច្ចព្រមព្រៀង ភាពជាដៃគូរពាណិជ្ជកម្ម រវាងរដ្ឋនិងរដ្ឋ, ខេត្ត និងខេត្ត គឺជាវិធីសាស្ត្រដ៏ល្អបំផុត ដើម្បីធានាថាផលិតផលដែលបានផលិតមក គឺមានស្ថេភាពតម្រូវការ និងស្ថេភាពថ្លៃនៅលើទីផ្សារ និងអាចរក្សាបាននូវឧត្តមភាពប្រកួតប្រជែងក្នុងតំបន់ផងដែរ។ តម្លៃប្រេងឥន្ធនៈមានឥទ្ធិផលដោយផ្ទាល់លើកត្តាផលិតកម្ម ហេតុនេះនិន្នាការងាកមករកប្រភពថាមពលដែលមានស្ថេរភាពថ្លៃ ដែលជាប្រភពថាមពលស្អាត ដូចជាវារីអគីសនីជាដើម គឺយន្តការល្អមួយដើម្បីកាត់បន្ថយផលប៉ះពាល់ពីអតិផរណាលើតម្លៃប្រេងឥន្ធនៈ ។

  ការធ្វើពាណិជ្ជកម្ម តាមរយៈប្រព័ន្ធអនឡាញ(e-commerce) គឺជាជម្រើសល្អក្នុងយុគ្គសម័យឌីជីថលនេះ ដែលអនុញ្ញាតអោយពាណិជ្ជករធ្វើពាណិជ្ជកម្ម ដោយមិនចាំបាច់ធ្វើការទំនាក់ទំនងដោយផ្ទាល់នោះទេ។ ក្នុងសម័យឌីជីថលនេះ ពាណិជ្ជករខ្មែរ ឬសិប្បករ ឬកសិករខ្មែរ ក៏អាចដាក់បង្ហាញទំនិញរបស់ខ្លួននៅលើ platform online ដែលអនុញ្ញាតអោយ អ្នកលក់ និងអ្នកទិញអាចមើលឃើញទំនិញ និងធ្វើការជជែកគ្នានៅលើ online តែម្តង។ ប៉ុន្តែ e-commerce តម្រូវអោយពាណិជ្ជករត្រូវមានកាយល់ដឹងបន្ថែមលើវិស័យបច្ចេកវិទ្យា និងplatformទាំងនេះ។

  ការកែប្រែរបៀបរបបធ្វើកសិកម្ម ពីកសិកម្មបែបប្រពៃណីមកជាកសិកម្មបែបទំនើប ដើម្បីកាត់បន្ថយថ្លៃដើម ទទួលបានទិន្នផលខ្ពស់ មានសុវត្ថិភាព និងមិនមានការបំពុលដី ដើម្បីអាចធានាបាននូវចីរភាពនៃការធ្វើកសិកម្ម។ ដើម្បីគាំទ្រដល់វិស័យកសិកម្ម យើងត្រូវអភិវឌ្ឍន៍បន្ថែមលើប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ដើម្បីបង្កើនប្រសិទ្ធភាពស្រោចស្រព ដែលអាចកាត់បន្ថយការគំរាមកំហែងពីការប្រែប្រួលអាកាសធាតុ(គ្រោះរាំងស្ងួត)លើវិស័យកសិកម្មបាន។

- រវាងភាពខ្សោយ(Weakness) និងឱកាស(Opportunities)៖ ការលើកទឹកចិត្តនិងជំរុញអោយមានការបង្កើតនូវទីតាំងទេសចរណ៍ថ្មី និងប្លែកៗដើម្បីជំរុញដល់វិស័យទេសចរណ៍ក្នុងស្រុកអោយមានដំណើការកាន់តែខ្លាំង បង្កើនចរន្តសេដ្ឋកិច្ចក្នុងស្រុក។ ការលើកទឹកចិត្ត ជំរុញការវិនិយោគក្នុង វិស័យកែច្នៃផលិតផលកសិកម្មក្នុងស្រុក អោយទៅជាផលិតផលសំរេច ឬពាក់កណ្តាលសំរេចអោយបានច្រើនដើម្បីទទួលបានប្រាក់ចំណូលបន្ថែម និងបង្កើតការងារ និងតម្លៃបន្ថែមក្នុងស្រុកបានកាន់តែច្រើនឡើង។ ការចុះកិច្ចព្រមព្រៀងភាពជាដៃគូរពាណិជ្ជកម្ម ពិតជាផ្តល់ឱកាសល្អក្នុងការនាំចេញ ជាពិសេសផលិតផលស្បៀងអាហារ។ ការផលិតកសិផល ឬផលិតផលដែលមានសុវត្ថិភាពសំរាប់សុខភាព គឺជាកត្តាគន្លឹះក្នុងការប្រគួតប្រជែងលើទីផ្សារទាំងក្នុងស្រុក និងក្រៅស្រុក ហេតុនេះកសិករ ឬផលិតករ តម្រូវអោយគោរពតាមស្តងដារសុវត្ថិភាពជាចម្បង។ ស្វែងរកប្រភពថាមពលដែលមាតម្លៃទាប សំរាប់វិស័យឧស្សាហាកម្ម គឺជាកត្តាសំខាន់ដើម្បីកាត់បន្ថយថ្លៃដើមផលិតកម្ម។

- រវាងភាពខ្សោយ(Weakness) និងការគំរាមកំហែង(Threats)៖ ឥទ្ធិពលសង្គ្រាមពាណិជ្ជកម្ម រវាងមហាអំណាចសេដ្ឋកិច្ចពិភពលោក សង្គ្រាមរុស្ស៊ី អ៊ុយក្រែន ពិតណាស់តែងតែមាន ឥទ្ធិពលមកលើសេដ្ឋកិច្ចពាណិជ្ជកម្ម កម្ពុជាក៏ដូចជាខេត្តត្បូងឃ្មុំដែរ ឥទ្ធិពលបែបនេះយើងគួរស្វែងរកវិធីកាត់បន្ថយនូវឥទ្ធិពលទាំងនោះដោយត្រូវស្វែងរកទីផ្សារថ្មីសំរាប់កម្ពុជា ដែលជាប្រទេសមិនមែនស្ថិតក្នុងប្លុកសង្គ្រាមខាងលើ។ ការប្រែប្រួលអាកាសធាតុ គឺជាលទ្ធផលនៃសកម្មភាពមួយចំនួន ដែលប៉ះពាល់ដល់

បរិស្ថាន តម្រូវអោយយើងមានការយកចិត្តទុកដាក់ខ្ពស់ កំឡុងពេលមានការអភិវឌ្ឍន៍ ពោលគឺត្រូវកាត់បន្ថយផលប៉ះពាល់ ដល់បរិស្ថានជាអតិបរាតាមដែលអាចធ្វើទៅបាន។ ភាពរាំងស្ងួត និងគ្រោះទឹកជំនន់ គឺជាកត្តាធម្មជាតិ ដែលមិនអាចគ្រប់គ្រងបាន ប៉ុន្តែតាមរយៈបច្ចេកទេសថ្មីៗ ក្នុងវិស័យកសិកម្ម យើងពិតជាអាចកាត់បន្ថយនូវផលប៉ះពាល់ទាំងនេះ ដូចជា ការអភិវឌ្ឍន៍ពូជដំណាំដែលធន់នឹងភាពរាំងស្ងួត ពូជដំណាំដែលអោយផលក្នុងរយៈពេលខ្លី និងអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ដើម្បីធានាដល់ការស្រោចស្រពជាដើម។

## ៤-សេចក្តីសន្និដ្ឋាន

យោងលើទីតាំងភូមិសាស្ត្ររបស់ខេត្តត្បូងឃ្មុំ និងចំនួនប្រជាជនជាង៨៦ម៉ឺននាក់ មានដង់ស៊ីតេប្រជាជនជាមធ្យម ១៦៨នាក់/គ.ម² ប្រជាជនមានអាយុ១៨ ដល់៦០ឆ្នាំមានជាង៥៥% ខេត្តត្បូងឃ្មុំ គឺជាខេត្តដែលមានប្រជាជនរស់នៅ ច្រើនកុះករក្នុងតំបន់។ GDPជាមធ្យមសំរាប់មនុស្សម្នាក់ស្មើនឹង ១,៥៩៧ដុល្លារអាមេរិក។ សណ្ឋានដីមានលក្ខណៈអំណោយផល លើដំណាំកសិឧស្សាហកម្ម និងដំណាំផ្សេងៗមួយចំនួនដូចជា កៅស៊ូ ដំឡូងមី ពោត ស្វាយចន្ទី និងម្រេច។ កត្តារួមផ្សំទាំងនេះធ្វើអោយខេត្តត្បូងឃ្មុំ ក្លាយជាខេត្តមួយដែលមានសក្តានុពលខ្ពស់ ក្នុងការវិនិយោគលើឧស្សាហកម្ម និងសិប្បកម្មកែច្នៃមួយចំនួន ដែលអាចទាញយកវត្ថុធាតុដើម ដែលមានស្រាប់ដូចជា ឧស្សាហកម្មផលិតសំបកកង់រថយន្ត និងយានយន្តគ្រប់ប្រភេទ ឧស្សាហកម្មផលិតសំភារៈប្រើប្រាស់ធ្វើអំពីជ័រផ្សេងៗ។ ការកែច្នៃកសិផលនានា ឱ្យទៅជាផលិតផលសំរេច និងពាក់កណ្តាលសំរេច ដូចជា ដំឡូងមី គ្រាប់ស្វាយចន្ទី ម្រេច ពោតក់ជាដើម គឺជាសក្តានុពលរបស់ខេត្តដែលត្រូវអភិវឌ្ឍន៍បន្ថែម។ ការអភិវឌ្ឍន៍បន្ថែមលើជំនាញដែលមានស្រាប់ក្នុងវិស័យកសិក្ម និងបណ្តុះបណ្តាលបន្ថែម លើជំនាញវិជ្ជាជីវៈផ្សេងៗដល់យុវជន គឺជាផែនការអភិវឌ្ឍផ្នែកទន់សំរាប់ស្ថេភាពការងាររយៈពេលវែង។ ទន្ទឹមនឹងនេះប្រព័ន្ធធារាសាស្ត្រ ដែលគាំទ្រដល់ការស្រោចស្រព ដំណាំនៅមានកំរិតទាប មិនទាន់ឆ្លើយតបតាមតម្រូវការ របស់វិស័យកសិកម្មនៅឡើយ ប្រការនេះទាមទារអោយខេត្តត្រូវមានការ វិនិយោគបន្ថែមទៀតលើប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីធានាដល់ការស្រោចស្រពក្នុងវិស័យកសិកម្ម។

ការធ្វើឱ្យប្រសើឡើងនូវគមនាគមន៍ ដឹកជញ្ជូននៅមូលដ្ឋាន គឺជាផ្នែកមួយជួយសម្រួល និងគាំទ្រដល់ការធ្វើវិនិយោគក្នុងស្រុក ដោយកែសម្រួលនូវប្រព័ន្ធឡូជីស្ទិច សំរាប់ដឹកជញ្ជូនទំនិញ និងវត្ថុធាតុដើម ក្នុងតម្លៃទាប និងឆាប់រហ័ស។ ហេតុនេះការវិនិយោគរបស់រដ្ឋ លើការផ្លាស់ប្តូរពីផ្លូវគ្រួស មកជាផ្លូវកៅស៊ូ ឬបេតុងឱ្យបានច្រើន គឺជាយុទ្ធសាស្ត្រដ៏ល្អបំផុតក្នុងការអភិវឌ្ឍន៍វិស័យដឹកជញ្ជូនក្នុងស្រុក។ ក្នុងវិស័យហិរញ្ញវត្ថុ ថ្វីត្បិតតែខេត្តត្បូងឃ្មុំមានសម្ពាធឥណទានល្អ ប៉ុន្តែតម្រូវការប្រាក់កម្ចី នៅតែខ្ពស់ និងមានការកើនឡើងដដែលជាពិសេស ក្នុងវិស័យកសិកម្ម។ ដើម្បីជៀសវាង នូវបំណុលវណ្ឌកេរ ប្រជាជននៅតែត្រូវការប្រភពឥណទាន ដែលមានអត្រាការប្រាក់ទាប ពោលគឺមានលក្ខណៈ សមស្របសំរាប់យកមក ពង្រីកអាជីវកម្មរបស់ខ្លួនក្នុងវិស័យកសិកម្ម។ កិច្ចសម្របសម្រួលមួយ គួរត្រូវបានធ្វើឡើងដើម្បីផ្តល់ឱកាស អោយប្រតិបត្តិករហិរញ្ញវត្ថុ ធ្វើប្រតិបត្តិការប្រាក់កម្ចីនៅក្នុងខេត្តដូចជា ធនាគារអភិវឌ្ឍន៍កសិកម្ម និងជនបទជាដើម ដើម្បីផ្តល់លទ្ធភាពអោយមានលំហូរទុនបន្ថែម លើវិស័យកសិកម្ម និងសិប្បកម្មកែច្នៃកសិផល។ ចំពោះវិស័យសុខាភិបាល ក្នុងខេត្តត្បូងឃ្មុំ នៅមានកំរិតទាប

នៅឡើយ ដោយហេតុថាប្រជាជនមកទទួល សេវាសុខាភិបាលនៅតាមបណ្តា ក្រុង/ស្រុក មានចំនួនតិចតួច ប្រការនេះបង្ហាញថាការផ្តល់សេវាសុខាភិបាល នៅមូលដ្ឋានមិនទាន់ឆ្លើយតប គ្រប់គ្រាន់តាមតម្រូវការនៅឡើយ ពិសេសគ្រូពេទ្យនៅមានចំនួនតិចលើកលែងក្រុងសួង។ ដោយឡែកវិស័យអប់រំនៅមានកំរិតទាប អត្រាបោះបង់ការសិក្សារខ្ពស់ អាចមានផលអវិជ្ជមានសំរាប់ការអភិវឌ្ឍន៍ខេត្តនាពេលអនាគត។ ចំនួនសិស្សដែលបោះបង់ការសិក្សា នៅថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យមានអត្រាខ្ពស់ កត្តានេះអាចមានឥទ្ធិពល លើគុណភាពនៃកំលាំងពលកម្មរបស់ខេត្តនៅថ្ងៃអនាគត់។ ការបង្កើតកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជនដែលបញ្ចប់ការសិក្សាក្រោមកំរិតទី១២ ដើម្បីផ្គត់ផ្គង់ តម្រូវការទីផ្សារការងារតាមវិស័យមួយចំនួនដូចជាសេវាកម្ម ឧស្សាហាកម្ម និងសិប្បកម្ម គឺជាកត្តាបុរេលក្ខនៈ ដើម្បីត្រៀមខ្លួនទុកជាមុនសំរាប់តម្រូវការក្នុងខេត្ត និងការអភិវឌ្ឍន៍នាពេលអនាគត។

ជារួម ខេត្តត្បូងឃ្មុំមានលក្ខណៈអំណោយផល ផ្នែកកសិកម្ម ឧស្សាហាកម្ម និងសិប្បកម្មកែច្នៃកសិផល ដើម្បីនាំចេញជាច្រើនប្រភេទ ដូចដែលបានរៀបរាបខាងលើ ព្រមទាំងកំលាំងពលកម្មគ្រប់គ្រាន់ ដើម្បីបម្រើការងារក្នុងវិស័យនីមួយ បូករួមទាំងទីតាំងភូមិសាស្រ្តមានលក្ខណៈអំណោយផលល្អផង ជាខេត្តជាប់ព្រំដែនផង ធ្វើអោយខេត្តត្បូងឃ្មុំ គឺជាខេត្តមួយមានសក្តានុពល ដែលអ្នកវិនិយោគអាចមានទំនុកចិត្ត និងឱកាសខ្ពស់ក្នុងការបណ្តាក់ទុនវិនិយោគទាំងផ្នែកសេវាកម្ម សិប្បកម្ម និងឧស្សាហាកម្ម។ បន្ទាប់ពីធ្វើការវិភាគស៊ីជម្រៅលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែងរួចមក យើងអាចធ្វើការកំណត់បានកាន់តែច្បាស់ និងអាចដាក់ចេញនូវផែនការយុទ្ធសាស្រ្តនានា ដើម្បីធ្វើការអភិវឌ្ឍន៍ខេត្ត ស្របតាមសក្តានុពល ដែលខេត្តត្បូងឃ្មុំមាន ម៉្យាងទៀតតាមរយៈការវិភាគខាងលើយើងពិតជាអាចបញ្ចៀសបាន នូវហានិភ័យនានាដែលអាចកើតមាន និងដើម្បីចាប់យកឱកាសសម្រាប់ខេត្តត្បូងឃ្មុំ ព្រមទាំងអាចដាក់ចេញនូវយុទ្ធសាស្រ្តក្នុងការ កែប្រែចំនុចខ្សោយរបស់ខេត្ត ឱ្យក្លាយទៅជាភាពខ្លាំងវិញជាក់ជាមិនខាន។

# ឯកសារយោង


- កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខេត្តត្បូងឃ្មុំ ឆ្នាំ២០២២
- ឯសារព័ត៌មានស្ថានភាពស្តីពីសេដ្ឋកិច្ច សង្គមឆ្នាំ ២០២៣ របស់មន្ទីរផែនការខេត្តត្បូងឃ្មុំ
- ត្បូងឃ្មុំខេត្តថ្មីលើទឹកដីចាស់, ផ្សព្វផ្សាយដោយសាលាខេត្តត្បូងឃ្មុំឆ្នាំ២០១៧
- របាយការណ៍ស្តីអំពីស្ថានភាពឥណទាននៅកម្ពុជាសម្រាប់ឆ្នាំ២០២២ របស់ក្រុមហ៊ុន ក្រេឌីតប្យូរ៉ូ (ខេមបូឌា) ខូអិលធីឌី
- របាយការណ៍កសិកម្មខេត្តត្បូងឃ្មុំឆ្នាំ២០២២ របស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ
- ទិន្នន័យប្រព័ន្ធធារាសាស្ត្រឆ្នាំ២០១៩របស់មន្ទីរធនធានទឹក និងឧតុនិយមខេត្តត្បូងឃ្មុំ
- ទិន្នន័យតារាងដំណាំអចិន្ត្រៃ ក្នុងខេត្តត្បូងឃ្មុំរបស់មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំឆ្នាំ២០២២
- ទិន្នន័យស្ថិតិមណ្ឌលសុខភាព មន្ទីរពេទ្យ និងគ្រូពេទ្យរបស់មន្ទីរសុខាភិបាលខេត្តត្បូងឃ្មុំ
- ទិន្នន័យស្ថិតិចំនួនសាលា គ្រូបង្រៀន និងសិស្សរបស់មន្ទីរអប់រំ យុវជននិ ងកីឡាខេត្តត្បូងឃ្មុំ។
- ទិន្នន័យស្ថិតិទីតាំង ទេសចរណ៍ក្នុងខេត្តត្បូងឃ្មុំ របស់មន្ទីរទេសចរណ៍ខេត្តត្បូងឃ្មុំ
- https://opendevelopmentcambodia.net/km/news/
- https://www.tboungkhmum.gov.kh/detail/4228
- https://opendevelopmentcambodia.net/km/topics/agricultural-commodities-processing-and-products/
- https://www.scribd.com/document/199191208/Cross-SWOT-Analysis-docx
- https://www.creditbureau.com.kh/report-and-publication/other-report/

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១. តារាងដំណាំរយៈពេលវែងនិងរយៈពេលខ្លីមានផ្ទៃដីដាំដុះសរុបធំជាង១ពាន់ហ.តក្នុងមួយប្រភេទ

## តារាងស្ថិតិ ផលិតកម្មដំណាំកសិកម្ម រយៈពេលខ្លី របស់ខេត្តត្បូងឃ្មុំ

| ល.រ | រាយមុខ ដំណាំ | ផ្ទៃដីដាំដុះ (ហត) | | | ផ្ទៃដីប្រមូលផល (ហត) | | | ទិន្នផល (ត/ហត) | | បរិមាណផល (តោន) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ | រដូវប្រាំង | រដូវវស្សា | មធ្យម | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| | **ឆ្នាំ២០២៣** | | | | | | | | | | | | |
| ១ | ដំណាំស្រូវ | 12,035 | 76,520 | **88,555** | 12,035 | 76,445 | **88,480** | 4.480 | 3.530 | **4.005** | 53,918 | 269,818 | **323,736** |
| ២ | បន្លែគ្រប់មុខ | 1,045 | 915 | **1,960** | 1,045 | 915 | **1,960** | 17.050 | 17.230 | **17.140** | 17,820 | 15,770 | **33,590** |
| ៣ | ពោតក្រហម | 6,940 | 4,895 | **11,835** | 6,940 | 4,510 | **11,450** | 6.500 | 6.110 | **6.305** | 45,110 | 27,548 | **72,658** |
| ៤ | ដំឡូងមី | 195 | 52,680 | **52,875** | 195 | 52,680 | **52,875** | 15.000 | 19.370 | **17.185** | 2,925 | 1,020,243 | **1,023,168** |
| ៥ | ថ្នាំជក់ | 1,235 | - | **1,235** | 1,235 | - | **1,235** | 1.700 | - | **1.700** | 2,100 | - | **2,100** |
| | សរុប | **21,450** | **135,010** | **156,460** | **21,450** | **134,550** | **156,000** | | | | **121,873** | **1,333,379** | **1,455,252** |
| | **ឆ្នាំ២០២២** | | | | | | | | | | | | |
| ១ | ដំណាំស្រូវ | 11,950 | 76,430 | **88,380** | 11,950 | 75,905 | **87,855** | 4.452 | 3.453 | **3.953** | 53,200 | 262,114 | **315,314** |
| ២ | បន្លែគ្រប់មុខ | 880 | 865 | **1,745** | 880 | 865 | **1,745** | 17.700 | 17.120 | **17.410** | 15,580 | 14,810 | **30,390** |
| ៣ | ពោតក្រហម | 7,100 | 4,125 | **11,225** | 7,100 | 4,125 | **11,225** | 5.640 | 6.070 | **5.855** | 40,028 | 25,023 | **65,051** |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | ដំឡូងមី | 190 | 52,945 | **53,135** | 190 | 52,945 | **53,135** | 15.000 | 19.250 | **17.125** | 2,850 | 1,019,302 | **1,022,152** |
| ៥ | ថ្នាំជក់ | 1,550 | - | **1,550** | 1,550 | - | **1,550** | 1.710 | - | **1.710** | 2,653 | - | **2,653** |
| | សរុប | **21,670** | **134,365** | **156,035** | **21,670** | **133,840** | **155,510** | | | | **114,311** | **1,321,249** | **1,435,560** |

## តារាងស្តីពី ផលិតកម្មដំណាំកសិកម្ម រយៈពេលវែង របស់ខេត្តត្បូងឃ្មុំ

| **លរ** | **រាយមុខដំណាំ** | **ឆ្នាំ២០២២** | | | | **ឆ្នាំ២០២៣** | | | |
|---|---|---|---|---|---|---|---|---|---|
| | | **ផ្ទៃដីដាំដុះ** | **ផ្ទៃដីប្រ.ផល** | **ទិន្នផល** | **បរិ.ផល** | **ផ្ទៃដីដាំដុះ** | **ផ្ទៃដីប្រ.ផល** | **ទិន្នផល** | **បរិ.ផល** |
| | | **ហត** | **ហត** | **ត/ហត** | **តោន** | **ហត** | **ហត** | **ត/ហត** | **តោន** |
| ១ | ស្វាយចន្ទី | 8,985 | 8,290 | 1.400 | 11,628 | 7,920 | 7,675 | 1.47 | 11,289 |
| ២ | ស្វាយ(ស្វាយកែវល្មៀត) | 2,725 | 2,045 | 22.350 | 45,700 | 2,285 | 1,655 | 22.83 | 37,790 |
| ៣ | ម្រេច | 3,370 | 2,134 | 3.850 | 8,220 | 3,370 | 3,270 | 3.85 | 12,591 |
| ៤ | កៅស៊ូ | 93,702.42 | 64,863.61 | 1.500 | 97,295 | 111,071.19 | 79,456.68 | 1.50 | 119,185 |
| | សរុប | **108,782** | **77,333** | | **162,843** | **124,646** | **92,057** | | **180,855** |

ឧបសម្ព័ន្ធទី២. តារាងទីតាំងសេវាកកម្មនិងសិប្បកម្មឆ្នាំ២០២០ដល់ឆ្នាំ២០២៣

| ល.រ | សិប្បកម្ម | 2020 | 2021 | 2022 | 2023 | ចំនួនមនុស្សបំរើការងារ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទីតាំង | ចំនួនទីតាំង | ចំនួនទីតាំង | ចំនួនទីតាំង | សរុប | ស្រី |
| ១ | ម៉ាស៊ីនកិនស្រូវខ្នាតមធ្យមឬធំ | 688 | 258 | 751 | 899 | 1,171 | 444 |
| ២ | សិប្បកម្មផលិតទឹកសុទ្ធ | 102 | 36 | 94 | 119 | 454 | 239 |
| ៣ | សិប្បកម្មផលិតគ្រឿងសង្ហារឹមពីឈើ | 104 | 37 | 86 | 100 | 151 | 31 |
| ៤ | សិប្បកម្មឡឥដ្ឋ | 56 | 11 | 49 | 42 | 505 | 255 |
| ៥ | សិប្បកម្មផ្សេងៗ | 33 | 8 | 39 | 27 | 217 | 73 |
| ៦ | សិប្បកម្មផលិតពីផ្តៅ ឬស្សី ល្ពាក់ | 11 | 11 | 32 | 32 | 74 | 6 |
| ៧ | សិប្បកម្មផលិតពីដែក អាលុញមីញ៉ូម.. | 40 | 17 | 24 | 32 | 58 | 20 |
| ៨ | សិប្បកម្មកែឆ្នៃឬវិចខ្ចប់ផលនេសាទ | 13 | 3 | 18 | 16 | 57 | 31 |
| ៩ | សិប្បកម្មកែឆ្នៃឬវិចខ្ចប់គ្រាប់ធញ្ញជាតិ | 14 | 8 | 12 | 13 | 86 | 43 |
| ១០ | សិប្បកម្មត្បាញរវៃ | 12 | 11 | 10 | 12 | 12 | 12 |
| ១១ | ការធ្វើអាជីវកម្មផ្តល់ថាមពល | 9 | 6 | 9 | 15 | 42 | 12 |
| ១២ | សិប្បកម្មផលិតពីជ័រ | 15 | 22 | 9 | 13 | 113 | 48 |
| ១៣ | សិប្បកម្មចម្លាក់ពីស្ពាន់ ថ្ម ស្បែក | 17 | 11 | 6 | 9 | 14 | 1 |
| ១៤ | សិប្បកម្មផលិតអំបិល | 19 | 25 | 4 | 3 | 52 | 19 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | សរុប | 1,133 | 464 | 1,143 | 1,332 | 3,006 | 1,234 |

| ល.រ | **សេវាកម្ម** | 2020 | 2021 | 2022 | 2023 | ចំនួនមនុស្សបំរើការងារ | |
|---|---|---|---|---|---|---|---|
| | | ចំនួនទីតាំង | ចំនួនទីតាំង | ចំនួនទីតាំង | ចំនួនទីតាំង | សរុប | ស្រី |
| ១ | លក់គ្រឿងបរិភោគនិងទំនិញប្រើប្រាស់ | 3,584 | 922 | 4,176 | 4,312 | 5,962 | 3,881 |
| ២ | អាជីវកម្មខ្នាតតូច(លក់បាយ គុយទាវ..) | 1,020 | 297 | 1,263 | 1,299 | 2,151 | 1,357 |
| ៣ | លក់ខោអាវស្បែកជើង គ្រឿងក្រអូប | 1,098 | 285 | 1,079 | 1,146 | 1,595 | 1139 |
| ៤ | ជួសជុលឬលក់កង់ ម៉ូតូ | 796 | 200 | 864 | 996 | 1,264 | 339 |
| ៥ | សេវាកម្មខ្នាតតូច(កាត់សក់ ម៉ាស្សា..) | 517 | 194 | 580 | 682 | 911 | 530 |
| ៦ | លក់គ្រឿងអលង្ការ | 356 | 58 | 370 | 342 | 532 | 286 |
| ៧ | លក់សំភារៈសំណង់ | 297 | 90 | 343 | 377 | 889 | 373 |
| ៨ | ឱសថស្ថាននិងឱសថស្ថានរង | 244 | 50 | 262 | 312 | 471 | 243 |
| ៩ | លក់គ្រឿងអេឡិចត្រូនិក | 231 | 57 | 236 | 237 | 356 | 163 |
| ១០ | ជួសជុលគ្រឿងអេឡិចត្រូនិក | 211 | 48 | 223 | 238 | 313 | 303 |
| ១១ | ជួសជុលឬលក់គ្រឿងយន្តនិងឧបករណ៍កសិកម្ម | 233 | 75 | 219 | 237 | 455 | 148 |
| ១២ | លក់សំភារៈសិក្សានិងកីឡា | 99 | 51 | 112 | 127 | 205 | 130 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៣ | គ្លីនិច | 65 | 27 | 102 | 112 | 320 | 168 |
| ១៤ | លក់គ្រឿងសង្ហារឹម(តុ ទូ កៅអី) | 84 | 29 | 85 | 76 | 137 | 57 |
| ១៥ | ភោជនីយដ្ឋាន | 68 | 46 | 83 | 71 | 199 | 105 |
| ១៦ | ផ្ទះសំណាក់ | 92 | 29 | 79 | 105 | 328 | 188 |
| ១៧ | សណ្ឋាគារ | 8 | 1 | 5 | 8 | 65 | 37 |
| | សរុប | 9,003 | 2,459 | 10,081 | 10,677 | 16,153 | 9,447 |

# ឧបសម្ព័ន្ធទី៣. តារាងសង្ខេបស្ថិតិពីស្ថានភាពឥណទានក្នុងខេត្តត្បូងឃ្មុំ ឆ្នាំ២០២៣

| ល.រ | ឈ្មោះស្រុក/ខណ្ឌ/ក្រុង Name of District/ Capital | ចំនួនប្រជាជនសរុប Total Population | ចំនួនប្រជាជនគ្រប់អាយុ១៨ឆ្នាំ Adult Population (18 years and above) | ចំនួនអ្នកខ្ចី* Number of Borrowers | អត្រាអ្នកប្រើប្រាស់កម្ចីធៀបនឹងចំនួនប្រជាជនគ្រប់អាយុ Share of Borrowers as Percentage of Adult Population | អត្រាអ្នកប្រើប្រាស់កម្ចីជាស្ត្រី Share of Women Borrowers as Percentage of Total Borrowers | សមតុល្យប្រាក់កម្ចី** (លានរៀល^) Outstanding Balance (KHR) | អត្រាសមតុល្យប្រាក់កម្ចី Percentage Share of Outstanding Balance | សមតុល្យក្នុងមួយកម្ចី (លានរៀល^) Average Loan Size in KHR per Borrower | អត្រាសងត្រលប់យឺតលើសពី90ថ្ងៃ DPD 90+ |
|---|---|---|---|---|---|---|---|---|---|---|
| 1 | ក្រូចឆ្មារ (Krouch Chhmar) | 85,187 | 52,959 | 15,551 | 29.4% | 52.1% | 281,843 | 6.0% | 23 | 2.7% |
| 2 | ត្បូងឃ្មុំ (Tboung Khmum) | 176,802 | 109,500 | 46,538 | 42.5% | 52.7% | 1,087,359 | 23.3% | 20 | 3.9% |
| 3 | តំបែរ (Dambae) | 87,539 | 52,956 | 26,222 | 49.5% | 51.8% | 468,644 | 10.1% | 24 | 1.9% |
| 4 | ពញាក្រែក (Ponhea Kraek) | 147,310 | 94,747 | 42,240 | 44.6% | 51.8% | 1,075,003 | 23.1% | 47 | 2.5% |
| 5 | មេមត់ (Memot) | 152,082 | 95,565 | 39,362 | 41.2% | 52.2% | 725,870 | 15.6% | 24 | 4.6% |
| 6 | សួង (Suong) | 35,054 | 22,748 | 10,294 | 45.2% | 52.0% | 498,619 | 10.7% | 23 | 5.4% |
| 7 | អូររាំងឪ (Ou Reang Ov) | 79,761 | 49,432 | 25,434 | 51.5% | 53.9% | 522,854 | 11.2% | 27 | 2.9% |
| សរុប | Total | **763,735** | **477,907** | **205,641** | **43.0%** | **52.4%** | **4,660,193** | **100.0%** | **22** | **3.4%** |

*ចំណាំ* * ចំនួនអ្នកខ្ចី សំដៅទៅលើចំនួនប្រជាជន ក្រុមហ៊ុនឬសហគ្រាសដែលប្រើប្រាស់សេវាប្រាក់កម្ចីនៅក្នុងតំបន់

** សមតុល្យប្រាក់កម្ចី សំដៅទៅលើទំហំប្រាក់កម្ចីសរុបដែលប្រជាជន ក្រុមហ៊ុន ឬសហគ្រាសខ្ចីនៅក្នុងតំបន់

^ អត្រាប្តូរប្រាក់ 1USD= 4,085 រៀល ថ្ងៃទី31 ខែធ្នូ ឆ្នាំ2023

ឧបសម្ព័ន្ធទី៤. តារាងស្ថិតិទីតាំងផ្តល់សេវាសិខាភិបាលតាមបណ្តាក្រុងស្រុក

| លរ | កម្រិតសិក្សា | ២០២២ | | | | | | ២០២៣ | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ចំនួនវេជ្ជបណ្ឌិត | ចំនួនគ្រូពេទ្យ និងគិលានុបដ្ឋាក | បុគ្គលិកដទៃទៀត | ចំនួនអ្នកជំងឺ | ចំនួនគ្រែ | ដទៃទៀត | ចំនួនវេជ្ជបណ្ឌិត | ចំនួនគ្រូពេទ្យ និងគិលានុបដ្ឋាក | បុគ្គលិកដទៃទៀត | ចំនួនអ្នកជំងឺ | ចំនួនគ្រែ | ដទៃទៀត |
| ១ | មន្ទីរពេទ្យបង្អែកខេត្ត | 36 | 72 | 82 | ពិគ្រោះជំងឺក្រៅ=16127<br>សម្រាកពេទ្យ=6253 | 240 | | 49 | 99 | 95 | ពិគ្រោះជំងឺក្រៅ=28607<br>សម្រាកពេទ្យ=11092 | 240 | |
| ២ | មន្ទីរពេទ្យបង្អែកក្រុងស្រុក | 60 | 95 | 179 | ពិគ្រោះជំងឺក្រៅ=35673<br>សម្រាកពេទ្យ=17439 | 347 | | 71 | 112 | 188 | ពិគ្រោះជំងឺក្រៅ=50117<br>សម្រាកពេទ្យ=20147 | 347 | |
| ៣ | មណ្ឌលសុខភាព | 5 | 239 | 413 | ពិគ្រោះជំងឺក្រៅ=520429 | - | | 3 | 245 | 443 | ពិគ្រោះជំងឺក្រៅ=545507 | - | |

ឧបសម្ព័ន្ធទី៥. តារាងស្ថិតិសាលារៀន គ្រូបង្រៀន និងសិស្សឆ្នាំ២០២២

| ល.រ. | | តំបែរ | ក្រូចឆ្មារ | មេមត់ | អូររាំងឪ | ពញាក្រែក | ស្ទួង | ត្បូងឃ្មុំ | សរុប |
|---|---|---|---|---|---|---|---|---|---|
| ១ | ចំនួនសាលាមត្តេយ | 38 | 50 | 61 | 19 | 96 | 6 | 37 | 307 |
| ២ | ចំនួនសាលាបឋមសិក្សា | 53 | 46 | 116 | 25 | 68 | 11 | 85 | 404 |
| ៣ | ចំនួនសាលាអនុវិទ្យាល័យ | 8 | 14 | 13 | 5 | 12 | 3 | 14 | 69 |
| ៤ | ចំនួនសាលាវិទ្យាល័យ | 3 | 9 | 5 | 2 | 4 | 1 | 7 | 31 |
| | **សរុបចំនួនសាលា** | **102** | **119** | **195** | **51** | **180** | **21** | **143** | 739 |
| ១ | គ្រូមត្តេយ | 32 | 88 | 92 | 56 | 84 | 31 | 99 | 482 |
| ២ | គ្រូបឋមសិក្សា | 432 | 359 | 611 | 239 | 546 | 164 | 618 | 2,969 |
| ៣ | គ្រូអនុវិទ្យាល័យ | 67 | 91 | 164 | 109 | 153 | 34 | 156 | 774 |
| ៤ | គ្រូវិទ្យាល័យ | 123 | 128 | 129 | 73 | 151 | 103 | 245 | 952 |
| | **សរុប ចំនួនគ្រូបង្រៀន** | **654** | **666** | **996** | **477** | **934** | **332** | **1,118** | **5,177** |
| | | | | | | | | | |
| ១ | សរុបកុមារអាយុ៣-៥ឆ្នាំ | 6,385 | 6,875 | 10,811 | 6,721 | 10,309 | 2,328 | 12,721 | 56,150 |
| | ចំនួនសិស្សមត្តេយសិក្សា | 3,497 | 4,041 | 5,489 | 2,822 | 6,927 | 1,212 | 4,863 | 28,851 |
| ២ | សរុបកុមារអាយុ៦ឆ្នាំ | 11,970 | 11,086 | 18,173 | 10,794 | 17,602 | 4,720 | 22,356 | 96,701 |
| | ចំនួនសិស្សានុសិស្សបឋមសិក្សា | 12,078 | 11,795 | 19,283 | 12,323 | 19,266 | 5,179 | 25,106 | 105,030 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៣ | សរុបកុមារអាយុ១២-១៤ឆ្នាំ | 6,362 | 6,175 | 10,179 | 6,166 | 9,802 | 2,786 | 13,009 | 54,479 |
| | ចំនួនសិស្សានុសិស្សអនុវិទ្យាល័យ | 5,371 | 6,123 | 9,368 | 6,027 | 8,785 | 2,757 | 12,598 | 51,029 |
| ៤ | ចំនួនអ្នកមានអាយុ១៥-១៧ឆ្នាំ | 7,369 | 5,832 | 10,272 | 6,477 | 9,286 | 2,883 | 13,531 | 55,650 |
| | ចំនួនសិស្សានុសិស្សវិទ្យាល័យ | 3,413 | 4,090 | 5,622 | 3,434 | 5,930 | 2,191 | 7,286 | 31,966 |
| | សរុបចំនួនមនុស្សក្នុងវ័យសិក្សា | 32,086 | 29,968 | 49,435 | 30,158 | 46,999 | 12,717 | 61,617 | 262,980 |
| | **សរុបចំនួនសិស្ស** | **24,359** | **26,049** | **39,762** | **24,606** | **40,908** | **11,339** | **49,853** | **216,876** |
| | ផលធៀបចំនួនចំនួនសិស្ស និងមនុស្សក្នុងវ័យសិក្សា | 76% | 87% | 80% | 82% | 87% | 89% | 81% | 83% |